

## ការបង្ហាញ និងបទពិសោធន៍របស់ជនរងគ្រោះស្តីពីៈ
## ភាពឆាប់ត្រលប់មកធម្មតាវិញ

# របាយការណ៍សង្ខេបសម្រាប់ការអនុវត្តន៍

## គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង

ជាគម្រោងស្រាវជ្រាវរបស់អង្គការសម្ព័ន្ធចាប់ដៃអំពីសមាហរណកម្ម ដែលសិក្សាទៅលើវដ្តជីវិតនៃជន ដែលត្រូវបានគេកេងប្រវ័ញ្ច និងជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា


របាយការណ៍ ខែធ្នូ ឆ្នាំ២០១៤
អ្នកនិពន្ធ៖ ថដ ម៉ូរីសុន
សហការីនិពន្ធ៖ ស៊ីវន ម៉ាលយ៍, ហៀង សុផល, លឹម វណ្ណធារី, ស្រៀង ផល្លី, និងញ៉ាញ់ ចន្ថា


សម្ព័ន្ធចាប់ដៃ
CHAB DAI COALITION

equitas.
LOVE146.ORG
end child sex slavery & exploitation
TENTH CHURCH
imago dei fund
EARTH HEIR

# សេចក្តីថ្លែងអំណរគុណ

ដើម្បីឲ្យការស្រាវជ្រាវនេះមានដំណើរការ យើងសហការដៃគូរជាមួយមនុស្ស និងអង្គការនានាជាច្រើន និងបានទទួលនូវការឧបត្ថម្ភគាំទ្រយ៉ាងមុតមាំពីម្ចាស់ជំនួយនៅក្នុងគម្រោងនេះ។ យើងសូមថ្លែងអំណរអគុណយ៉ាងជ្រាលជ្រៅដល់ Equitas ដែលជាម្ចាស់ជំនួយធំបំផុតរបស់គម្រោង ចំពោះការជឿជាក់ និងការបន្តផ្តល់ជំនួយដល់គម្រោងនេះតាំងពីឆ្នាំកន្លងៗមក។ យើងក៏សូមអរគុណដល់ម្ចាស់ជំនួយដទៃទៀតដូចជា Tenth, Imago Dei, LOVE146, Earth Heir និងបណ្តាម្ចាស់ជំនួយផ្សេងៗទៀតសម្រាប់ការឧបត្ថម្ភទាំងផ្នែកហិរញ្ញវត្ថុ និងការលើកទឹកចិត្ត។

យើងសូមអរគុណចំពោះអង្គការដៃគូរជាមួយគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង។ យើងពិតជាកោតសរសើររាល់ការខ្នះខ្នែងជួយសម្របសម្រួល និងការផ្តល់ព័ត៌មាន ដែលទាក់ទងទៅនឹងអតិថិជននៅក្នុងគម្រោង។ យើងក៏សូមអរគុណចំពោះការចូលរួមផ្តល់ជាមតិវាយតម្លៃលើលទ្ធផលនៃការសិក្សា និងអនុសាសន៍នានានៅក្នុងរបាយការណ៍សិក្សារបស់យើង។ ជាពិសេស យើងក៏សូមអរគុណចំពោះអង្គការមួយចំនួនដូចជា Agape International Mission (AIM), American Rehabilitation Ministries (ARM) នៅបាត់ដំបង និងសៀមរាប, Bloom Asia, Cambodian Hope Organization (CHO), Citipointe International Care & Aids (SHE Rescue Home), Daughters Organization, Destiny Rescueses, Hagar Cambodia, Health Care Center for Children (HCC), International Justice Mission (IJM), Pleroma Home for Girls, Garden of Hope in Cambodia, Ratanak International, Transition Global, World Hope International និងWorld Vision។

យើងក៏សូមថ្លែងអំណរអរគុណចំពោះអ្នកដែលបានចូលរួមចំណែកក្នុងគម្រោងដូចខាងក្រោមៈ

- លោកស្រី ហេឡេន ស្វ៊ន ជាស្ថាបនិក និងជានាយិកាអន្តរជាតិនៃអង្គការសម្ព័ន្ធចាប់ដៃ សម្រាប់ទស្សនវិស័យ ការណែនាំ និងទឹកចិត្តដ៏មុតមាំចំពោះការស្រាវជ្រាវនេះ។
- លោក រស់ យ៉េង ជានាយកប្រចាំប្រទេសនៃអង្គការសម្ព័ន្ធចាប់ដៃ ចំពោះការគាំទ្រ និងការលើកទឹកចិត្ត។

- កញ្ញា អោង មុយឡេន នាយិកាប្រតិបត្តិ និងហិរញ្ញវត្ថុនៃអង្គការសម្ព័ន្ធចាប់ដៃ ចំពោះការខិតខំប្រឹងប្រែងមិនគិតពីការនឿយហត់ក្នុងការរៀបចំខ្ទង់ចំណាយ និងការទំនាក់ទំនងជាមួយម្ចាស់ជំនួយសម្រាប់គម្រោងនេះ។
- លោក ស៊ុន វារិទ្ធ អ្នកគ្រប់គ្រងជាន់ខ្ពស់នៃសម្ព័ន្ធរបស់អង្គការសម្ព័ន្ធចាប់ដៃ ចំពោះការគាំទ្រ និងការលើកទឹកចិត្ត។
- បណ្ឌិត Glenn Miles អ្នកប្រឹក្សាស្រាវជ្រាវសម្ព័ន្ធចាប់ដៃ ចំពោះគំនិត និងអនុសាសន៍។
- បណ្ឌិត Jill K. Reimer ចំពោះការរួមចំណែកជាមតិវាយតម្លៃ និងអនុសាសន៍ដ៏មានតម្លៃ។
- Rebecca Surtees ចំពោះការរួមចំណែកផ្តល់ជាមតិវាយតម្លៃ និងអនុសាសន៍ដ៏មានតម្លៃ។
- កញ្ញា ហាណា ស្វិន សម្រាប់ការអានពិនិត្យឡើងវិញលើរបាយការណ៍ប្រធានបទរួមនេះ។

ដើម្បីស្វែងរករបាយការណ៍សិក្សាប្រធានបទរួម "**បទពិសោធន៍ និងការបង្ហាញរបស់ជនរួចពីរងគ្រោះស្តីពី ភាពឆាប់ត្រលប់មកធម្មតាវិញ**" និងឯកសារយោងទាំងមូល សូមទៅមើលនៅក្នុង៖ Morrison, Todd. Miles, Siobhan. Schafer, Priscilla. Heang, Sophal. Lim, Vanntheary. Sreang, Phally. and Nhanh, Channtha. (2014), 'Resilience: Survivor Experiences and Expressions ', *The Butterfly Longitudinal Research Project: A Chab Dai study on (Re-) integration: Researching the lifecycle of sexual exploitation & trafficking in Cambodia* (Phnom Penh: Chab Dai).

www.freedomcollaborative.org/library

and/or

www.chabdai.org.

# មាតិកា


**1.0** សេចក្តីផ្តើម ........ 1

**1.1** កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ ........ 1

**2.0** វិធីសាស្ត្រស្រាវជ្រាវ ........ 2

**3.0** លទ្ធផលនៃការសិក្សា និងសេចក្តីសន្និដ្ឋាន ........ 4

**3.1** កត្តាចម្បងៗស្តីពីសុខុមាលភាពផ្ទាល់ខ្លួន ........ 4

3.1.1 ទំនាក់ទំនង ........ 4

3.1.2 ការរើសអើង ........ 10

3.1.3 កត្តារុញច្រាន ........ 14

3.1.4 ឱកាសការងារ និងការរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ........ 14

3.1.5 ការបង្ហាញអំពីសុខុមាលភាព ........ 18

**3.2** ការសិក្សាស្រាវជ្រាវរយៈពេលវែង ........ 20

3.2.1 ចំណុចឡើងចុះវិជ្ជមាន និងអវិជ្ជមានសំខាន់ៗ ........ 21

3.2.2 ការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងសហគមន៍ ........ 23

3.2.3 ការបញ្ចេញមតិអំពីភាពឆាប់ត្រលប់មកធម្មតាវិញ ........ 26

**4.0** លទ្ធផលនៃការសិក្សា និងអនុសាសន៍ ........ 28

**5.0** ឯកសារយោង ........ 32

# បញ្ជីតារាង និងក្រាហ្វិក

តារាងទី 1៖ ស្ថិតិចំនួនអតិថិជននៅក្នុងការសិក្សា តាំងពីឆ្នាំ 2011 ដល់ឆ្នាំ2014........................................3
ក្រាហ្វិកទី 1៖ ទំនាក់ទំនងរបស់ក្រុមស្ត្រី/ក្មេងស្រីជាមួយនឹងដៃគូ និងប្តី ឆ្នាំ2011ដល់2014.....................6
ក្រាហ្វិកទី 2៖ ទំនាក់ទំនងរបស់ក្រុមបុរស/ក្មេងប្រុសជាមួយនឹងសមាជិកគ្រួសារ ឆ្នាំ2011 ដល់ឆ្នាំ2014 ....................................................................................................................................8
ក្រាហ្វិកទី 3៖ ទំនាក់ទំនងរបស់ក្រុមស្ត្រី/ក្មេងស្រីជាមួយសមាជិកគ្រួសារក្រៅពីប្តី ឆ្នាំ2011ដល់ឆ្នាំ2014 ....................................................................................................................................9
ក្រាហ្វិកទី 4៖ បទពិសោធន៍អតិថិជនជាបុរស/ក្មេងប្រុស ដែលធ្វើសមាហរកម្មរួចក្នុងសហគមន៍ ឆ្នាំ 2011-2014 ........................................................................................................................12
ក្រាហ្វិកទី 5៖ បទពិសោធន៍អតិថិជនជាស្ត្រី/ក្មេងស្រីដែលធ្វើសមាហរកម្មរួចក្នុងសហគមន៍ ឆ្នាំ2011-2014..............................................................................................................................13
ក្រាហ្វិកទី 6 ៖ ការរកប្រាក់ផ្គត់ផ្គង់គ្រួសារបន្ទាប់ពីធ្វើសមាហរណកម្មរបស់ក្រុមស្ត្រី/ក្មេងស្រី ឆ្នាំ 2011-2014..............................................................................................................................16
ក្រាហ្វិកទី 7៖ ការរកប្រាក់ផ្គត់ផ្គង់គ្រួសារបន្ទាប់ពីធ្វើសមាហរណកម្មរបស់ក្រុមបុរស/ក្មេងប្រុស ឆ្នាំ 2011-2014 ........................................................................................................................17

# 1.0 សេចក្តីផ្តើម

ឯកសារនេះ គឺជារបាយការណ៍សិក្សាសង្ខេបដកស្រង់ពីរបាយការណ៍សិក្សាប្រធានបទរួមអំពី *"បទពិសោធន៍ និងការបង្ហាញរបស់ជនរួចពីរងគ្រោះស្តីពីភាពឆាប់ត្រលប់មកធម្មតាវិញ"*។ របាយការណ៍នេះមានបង្ហាញនូវលទ្ធផលនៃការសិក្សាសង្ខេប ដែលបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវលើប្រធានបទរួមស្តីពីភាពឆាប់ត្រលប់មកធម្មតាវិញ។ របាយការណ៍សង្ខេបនេះក៏មានបញ្ចូលនូវ អនុសាសន៍មួយចំនួនសម្រាប់អង្គការ ដែលធ្វើការប្រយុទ្ធប្រឆាំងនឹងការជួញដូរនៅក្នុងប្រទេសកម្ពុជា ដែលធ្វើការជាមួយជនរងគ្រោះ ឬជនរួចពីរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ។ វិធីសាស្ត្រស្រាវជ្រាវ លទ្ធផលនៃការសិក្សា និងសេចក្តីសន្និដ្ឋាន ត្រូវបានបកស្រាយយ៉ាងលំអិតនៅក្នុងរបាយការណ៍សិក្សាប្រធានបទរួមទាំងមូល។

## 1.1 កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ

គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែង គឺជាការសិក្សារយៈពេលវែងដំបូងគេ ដែលធ្វើការសិក្សាតាមដានទៅលើកុមារ និងមនុស្សធំ ដែលជាជនរួចពីរងគ្រោះដោយសារការកេងប្រវ័ញ្ច និងការជួញដូរផ្លូវភេទ ដែលចាប់ផ្តើមធ្វើការតាមដាន ចាប់តាំងពីពេលពួកគេរស់នៅក្នុងកម្មវិធីថែទាំរហូតដល់ពេលពួកគេធ្វើសមាហរណកម្ម។ ការសិក្សាស្រាវជ្រាវរយៈពេលវែងនេះរៀបចំឡើងដោយឆ្លើយតបទៅនឹងដែនកំណត់សិក្សាសំខាន់ៗ ដែលប្រើនៅក្នុងប្រភេទការសិក្សាស្រាវជ្រាវតាមចន្លោះពេលវេលាទៅលើការធ្វើសមាហរណកម្មរបស់ជនរួចពីរងគ្រោះ (Derks et al. 2006; Reimer et al. 2007; Surtees 2013)។ គម្រោងនេះធ្វើការសិក្សាតាមដានទៅលើជនរួចពីរងគ្រោះមួយក្រុម ដែលបានជ្រើសរើសនៅក្នុងប្រទេសកម្ពុជា ហើយបានប្រមូលទិន្នន័យយ៉ាងច្រើនរួចទៅហើយ តាំងពីឆ្នាំ2011 រហូតដល់ឆ្នាំ2014នេះ។ គោលបំណងនៅក្នុងការសិក្សានេះ គឺដើម្បីពង្រីកការយល់ដឹងឲ្យបានទូលំទូលាយស្តីអំពីដំណើរការនៃការធ្វើសមាហរណកម្មក្នុងរយៈពេលវែងរបស់ជនរួចពីរងគ្រោះ ថាតើពួកគេមានបទពិសោធន៍អ្វីខ្លះនៅពេលធ្វើសមាហរណកម្ម ហើយស្ថានភាពជីវិតរបស់ពួកគេនឹងទៅជាយ៉ាងណា ឆ្លងកាត់ពីមួយឆ្នាំទៅមួយឆ្នាំ។

គោលបំណងនៃរបាយការណ៍សិក្សានេះ គឺដើម្បីធ្វើការស្វែងយល់ឱ្យបានទូលំទូលាយអំពីភាពឆាប់ត្រលប់មកធម្មតាវិញ តាមរយៈ "សម្លេង" រួមរបស់ជនរួចផុតពីអំពើកេងប្រវ័ញ្ច និងការជួញដូរក្នុងប្រទេសកម្ពុជា។ តាមរយៈការបង្ហាញពី "សម្លេង" របស់ពួកគេ និងការផ្សព្វផ្សាយអំពីរបកគំហើញនៃការ

ស្រាវជ្រាវនេះ ទាំងនៅក្នុងស្រុក នៅក្នុងតំបន់ និងជាសាកល អង្គការសម្ព័ន្ធចាប់ដៃជឿជាក់ថា កម្មវិធី និងគោលនយោបាយធ្វើសមាហរណកម្មនានានឹងទទួលបានពត៌មានជាច្រើន និងមានភាពវិវត្តទៅមុខ ដើម្បីជួយឱ្យជីវិតរបស់ជន ដែលរួចផុតពីការកេងប្រវ័ញ្ចផ្លូវភេទ មានភាពប្រសើរឡើងទាំងនៅក្នុងអាស៊ីអាគ្នេយ៍ និងនៅជុំវិញពិភពលោក។

## 2.0 វិធីសាស្ត្រស្រាវជ្រាវ

គម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែងបានចាប់ផ្តើមរៀបចំឡើងតាំងពីឆ្នាំ2010 ហើយបានឈានដល់ឆ្នាំទី៥ នៅក្នុងខែធ្នូ២០១៤ នេះ។ សេចក្តីលំអិតទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវ ការផ្លាស់ប្តូរវិធីសាស្ត្រពីមួយឆ្នាំទៅមួយឆ្នាំ ក្រមសីលធម៌ស្រាវជ្រាវ ឧបករណ៍ និងវិធីសាស្ត្រប្រមូលទិន្នន័យ និងចំនុចខ្លាំងព្រមទាំងចំនុចខ្សោយនៃវិធីសាស្ត្រទាំងអស់នោះ អាចរកមើលបាននៅក្នុងរបាយការណ៍សិក្សាប្រចាំឆ្នាំ (សូមមើលនៅក្នុង Miles and Miles 2010; Miles and Miles 2011; Miles et al. 2012; Miles et al. 2013)

នៅពាក់កណ្តាលនៃអាយុគម្រោងស្រាវជ្រាវដ៏ធំមួយនេះ ក្រុមស្រាវជ្រាវបានសម្រេចចិត្តធ្វើការវិភាគករណីសិក្សាមូលដ្ឋានទៅលើជីវិតរបស់អតិថិជននីមួយៗ។ ទិន្នន័យទាំងបែបគុណវិស័យ និងបែបបរិមាណវិស័យប្រមូលបានជាងបួនឆ្នាំកន្លងមកនេះត្រូវបានប្រមូល និងសង្ខេបពត៌មានឡើងវិញ ដើម្បីស្វែងរកអ្វីដែលបានដឹង ពត៌មានដែលខុសពីសាច់រឿងមុនៗ និងការបាត់បង់សាច់រឿងរបស់អតិថិជនចូលរួមនីមួយៗ។ ករណីសិក្សានេះ ធ្វើការវិភាគទិន្នន័យសង្ខេបបែបគុណវិស័យចំពោះអតិថិជនចំនួន 86 នាក់ និងទិន្នន័យឆ្លើយតបនៅក្នុងបញ្ជីស្ទង់មតិរបស់អតិថិជនទាំង 128នាក់។ ទិន្នន័យទាំងអស់នេះបានក្លាយជាបណ្តុំទិន្នន័យសម្រាប់ ការសិក្សាស្រាវជ្រាវលើប្រធានបទរួមនេះ។

ការសិក្សាលើប្រធានបទរួមនេះ បានប្រើប្រាស់ទិន្នន័យដែលបានប្រមូលក្នុងរយៈពេល ៤ឆ្នាំ ជាប់ៗគ្នាពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ ដោយបានពីការធ្វើបទសម្ភាសន៍ចំនួន ៩៩៤លើក ជាមួយអតិថិជនចំនួន ១០៩នាក់។ ទិន្នន័យសង្ខេបដែលពាក់ព័ន្ធ ព្រមទាំងពត៌មានលំអិតៗ ក៏ត្រូវបានចងក្រង និងត្រួតពិនិត្យឡើងវិញ ដោយផ្អែកលើប្រធានបទចម្បងទាំង៦ ក្នុងការសិក្សាទាំងមូល។ ប្រធានបទទាំងនេះរួមបញ្ចូលនូវចំលើយរបស់អតិថិជន ដែលចូលរួមការសិក្សាស្រាវជ្រាវ អំពីឥរិយាបថ ផ្នត់គំនិត និងបទពិសោធន៍របស់ពួកគេ ទាក់ទងនឹង "ការជឿទុកចិត្ត" "ទំនាក់ទំនង" "បំណុល" "ស្លាកស្នាមទុយ៌ស" "ការរើសអើង" "អំពើហិង្សា" និង"សុខុមាលភាព"។

អតិថិជនត្រូវបានបែងចែកជា 4ក្រុម ដោយបែងចែកផ្អែកទៅតាមភេទ ហើយនិងរយៈពេល ដែលពួកគេស្នាក់ក្នុងកម្មវិធីមណ្ឌលយ៉ាងហោចណាស់ 4ខែ (មើលតារាងទី 1)។ អតិថិជនទាំង 4ក្រុមនេះរួមមានដូចខាងក្រោម៖

1. ស្ត្រី/ក្មេងស្រី ដែលស្នាក់នៅក្នុងកម្មវិធីជំនួយ ហើយមិនទាន់ធ្វើសមាហរណកម្ម (ចំនួន 32នាក់)
2. ស្ត្រី/ក្មេងស្រី ដែលបានស្នាក់នៅក្នុងកម្មវិធីជំនួយ ហើយបានធ្វើសមាហរណកម្មរួច (ចំនួន 34 នាក់)។
3. ស្ត្រី/ក្មេងស្រី ដែលធ្វើសមាហរណកម្មទៅសហគមន៍រួច តែមិនដែលបានស្នាក់នៅក្នុងកម្មវិធីជំនួយ (ចំនួន 28នាក់)។
4. បុរស/ក្មេងប្រុស ដែលបានស្នាក់នៅក្នុងកម្មវិធីជំនួយ ហើយបានធ្វើសមាហរណកម្មរួច (ចំនួន 15នាក់)។

**តារាងទី 1៖ ស្ថិតិចំនួនអតិថិជននៅក្នុងការសិក្សា តាំងពីឆ្នាំ 2011 ដល់ឆ្នាំ2014**

| Assessment Groups | Starting Ages | | Total Number of Individuals | Total Number of individual Years Assessed | Count of Individuals by the Number of Years Included in Longitudinal Assessment | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Shelter | | | | | Community | | | | |
| | Range | Average | | | 0 | 1 | 2 | 3 | 4 | 0 | 1 | 2 | 3 | 4 |
| Female SP | 7-20 | 14.3 | 32 | 99 | 0 | 1 | 6 | 14 | 11 | NA | | | | |
| Female RC | 16-36 | 24.6 | 28 | 84 | NA | | | | | 0 | 0 | 8 | 12 | 8 |
| Female SP/RC | 13-21 | 17 | 34 | 60 / 51 | 2 | 11 | 15 | 5 | 1 | 5 | 13 | 10 | 6 | 0 |
| Male SP/RC | 10-17 | 12.9 | 15 | 29 / 30 | 0 | 6 | 5 | 3 | 1 | 0 | 3 | 9 | 3 | 0 |

**ចំណាំ៖**

NA-គ្មានចម្លើយ

SP-កម្មវិធីមណ្ឌល

RC-អតិថិជនបានធ្វើសមាហរណកម្មទៅសហគមន៍

SP/RC-អតិថិជនក្នុងកម្មវិធីមណ្ឌល ហើយបានធ្វើសមាហរណកម្មទៅសហគមន៍

## 3.0 លទ្ធផលនៃការសិក្សា និងសេចក្តីសន្និដ្ឋាន

ការបង្ហាញពីភាពឆាប់ត្រលប់មកធម្មតាវិញរបស់ជនរួចពីរងគ្រោះ បានបង្ហាញអំពីសមត្ថភាពក្នុងការសម្របទៅនឹងស្ថានភាពលំបាកៗនៅក្នុងជីវិតរបស់ពួកគេ។ ជនរួចពីរងគ្រោះបានបង្ហាញពីអារម្មណ៍ស្តីពីសុខុមាលភាពរបស់ពួកគេ ហើយពេលខ្លះក៏បានបង្ហាញអំពីភាពជំនះតស៊ូនៅពេលបានជួបឧបសគ្គ និងបញ្ហាប្រឈមនានា។

### 3.1 កត្តាចម្បងៗស្តីពីសុខុមាលភាពផ្ទាល់ខ្លួន

ការសិក្សាស្រាវជ្រាវនេះផ្តោតចម្បងទៅលើបទពិសោធន៍ និងការបង្ហាញអំពីភាពឆាប់ត្រលប់មកធម្មតាវិញរបស់ជនរួចពីរងគ្រោះបន្ទាប់ពីធ្វើសមាហរណកម្ម។ កត្តា និងស្ថានភាពផ្សេងៗគ្នាស្តីពីភាពឆាប់ត្រលប់មកធម្មតាវិញ ត្រូវបានកំណត់ និងពិភាក្សាតាមរយៈការស្តាប់ពីសម្តីរួមរបស់ជនរួចពីរងគ្រោះ។ ការសិក្សានេះបានប្រមូលយកទិន្នន័យរយៈពេលវែង៤ឆ្នាំ ពីការស្ទង់មតិ និងការសម្ភាសន៍ជាមួយជនរួចពីរងគ្រោះនៅក្នុងប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះផ្តោតទៅចំនុចសំខាន់ដូចជា ការទំនាក់ទំនង ការរើសអើង និងទិដ្ឋភាពផ្សេងៗនៅក្នុងជីវិតដែលទាក់ទងទៅនឹងសុខុមាលភាព។

#### 3.1.1 <u>ទំនាក់ទំនង</u>

អតិថិជនមួយភាគធំនៅក្នុងការសិក្សាស្រាវជ្រាវនេះ បានកំពុងជួបប្រទះបញ្ហាទំនាក់ទំនងជាមួយ ប្តីប្រពន្ធ និងឪពុកម្តាយក្មេករបស់ពួកគេ។ នៅក្នុងក្រុមអតិថិជន ដែលមានអាយុច្រើនជាងគេបំផុតនៅក្នុងការសិក្សានេះ មានអតិថិជន 15នាក់ ក្នុងចំណោមអតិថិជន 19នាក់ដែលបានរៀបការហើយ ឬស្ថិតក្នុងទំនាក់ទំនងរយៈពេលវែង បាននិយាយរៀបរាប់ពីទំនាក់ទំនងអវិជ្ជមានជាមួយមិត្តប្រុស ឬប្តីប្រពន្ធ និង/ឬឪពុកម្តាយក្មេករបស់ពួកគេ នៅក្នុងបទសម្ភាសន៍ឆ្នាំមុនៗ (ក្រាហ្វិកទី 1)។ ហើយអតិថិជន 09នាក់ ក្នុងចំណោម 15នាក់នោះ បាននិយាយរៀបរាប់អំពីស្ថានភាពអវិជ្ជមាននេះរយៈពេលយូរគឺពី 2ឆ្នាំ ឬច្រើនឆ្នាំជាប់ៗគ្នា។ អតិថិជនភាគច្រើននិយាយអំពីការរស់នៅជាមួយគ្រួសារសាច់ថ្លៃបន្ទាប់ពីរៀបការរួច ហើយក៏បាននិយាយរៀបរាប់ពីបញ្ហាលំបាកនានាក្នុងការសម្របខ្លួនរស់នៅជាមួយគ្រួសារថ្មីនេះដែរ។ គួរឲ្យសោកស្តាយ អតិថិជនជាច្រើននាក់បាននិយាយអំពីការស៊ូទ្រាំអស់រយៈពេលជាច្រើនឆ្នាំរបស់ពួកគេទាក់ទងនឹងអំពើហិង្សាលើរាងកាយដោយសារគ្រឿងស្រវឹង ការរំលោភបំពានផ្នែកផ្លូវអារម្មណ៍ ការគំរាមកំហែងផ្នែករាងកាយ ភាពមិនស្មោះត្រង់ បញ្ហាញៀនគ្រឿងញៀន និងបញ្ហាការបោះបង់ចោល មិនទទួលស្គាល់ពីសំណាក់ប្តី ឬមិត្តប្រុស និងគ្រួសារសាច់ថ្លៃរបស់ពួកគេ។ ទោះបីជាអតិថិជនដែលរៀបការ

ហើយមានចំនួនតិចតួចក៏ដោយបើប្រៀបធៀបទៅនឹងក្រុមអតិថិជនផ្សេងៗទៀតក្នុងការសិក្សានេះ ពួកគេនៅតែបានជួបប្រទះបញ្ហាពិបាកស្រដៀងគ្នាដែរ ក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ ដែលចេះលើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមក។ ខាងក្រោមជាពាក្យសម្តី ដែលជនរួចពីរងគ្រោះបានរៀបរាប់ពីបទពិសោធន៍របស់ពួកគេ៖

⇒ *ប្រុសៗបានបោកប្រាស់ខ្ញុំម្តងហើយម្តងទៀត។ ខ្ញុំមិនចង់មានទំនាក់ទំនងជាមួយមនុស្សប្រុសទៀតទេព្រោះការស្រលាញ់បែបនេះធ្វើអោយខ្ញុំខូចចិត្ត និងឈឺចិត្តយ៉ាងខ្លាំង។ - ស្ត្រីរួចពីរងគ្រោះ អាយុ 23ឆ្នាំ និយាយពីបទពិសោធន៍នេះក្នុងឆ្នាំ2013។*

⇒ *ខ្ញុំផឹកស្រាព្រោះអីរៀងរាល់យប់ខ្ញុំតែងមិនលក់ដោយសារខ្ញុំមានអារម្មណ៍តានតឹង ស្មុគស្មាញច្រើនជាមួយប្តីរបស់ខ្ញុំ ព្រោះគាត់មិនសូវត្រលប់មកផ្ទះញឹកញាប់ណាស់ ហើយពេលខ្លះគាត់វាយធ្វើបាបខ្ញុំទៀត។ - ស្ត្រីរួចពីរងគ្រោះ អាយុ33ឆ្នាំ និយាយពីបទពិសោធន៍នេះក្នុងឆ្នាំ 2012។*

ក្រាហ្វិកទី 1៖ ទំនាក់ទំនងរបស់ក្រុមស្ត្រី/ក្មេងស្រីជាមួយនឹងដៃគូ និងប្តី ឆ្នាំ2011ដល់2014



ទំនាក់ទំនងជាមួយម្តាយ គឺជាទំនាក់ទំនងគ្រួសារមួយដ៏សំខាន់បំផុត ដែលបាននិយាយបញ្ជាក់ដោយអតិថិជនវ័យក្មេងមួយចំនួន ដែលកំពុងរស់នៅក្នុងមណ្ឌល និងក្នុងសហគមន៍។ ទំនាក់ទំនងល្អរវាងម្តាយ និងជនរួចពីរងគ្រោះវ័យក្មេង អាចមានការជះឥទ្ធិពលជាវិជ្ជមានគួរឲ្យកត់សម្គាល់ទៅលើភាពឆាប់ត្រលប់មកធម្មតាវិញរបស់ជនរួចពីរងគ្រោះក៏ដូចជាជួយពួកគេនៅពេលពួកគេក្លាយជាយុវវ័យដែរ។ អតិថិជនមួយចំនួនបាននិយាយពីចំនុចនេះដូចខាងក្រោមៈ

⇒ *ទោះបីជាគ្រួសារខ្ញុំក្រ ប៉ុន្តែពួកយើងរស់នៅជាមួយគ្នាយ៉ាងសប្បាយដោយមិនដែលមានការឈ្លោះទាស់ទែងគ្នាទេ។ - ស្ត្រីរួចពីរងគ្រោះ អាយុ19ឆ្នាំ និយាយពីបទពិសោធន៍នេះក្នុងឆ្នាំ 2013។*

⇒ *រាល់ពេលដែលខ្ញុំមានបញ្ហា ម្តាយរបស់ខ្ញុំតែងតែលួបលោមខ្ញុំ។ ខ្ញុំទុកចិត្តឪពុកម្តាយខ្ញុំជាងគេបំផុត។ - ស្ត្រីរួចពីរងគ្រោះ អាយុ16ឆ្នាំ និយាយពីបទពិសោធន៍នេះក្នុងឆ្នាំ2013។*

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បញ្ហាគ្រួសារ និងបញ្ហាទំនាក់ទំនងតែងតែកើតឡើងមិនចេះដាច់ ហើយក៏ជាប្រធានមួយ ដែលបានលើកមកសិក្សាជាប្រចាំពីមួយឆ្នាំទៅមួយឆ្នាំជាមួយនឹងអតិថិជន ដែលបានធ្វើសមាហរណកម្ម (ក្រាហ្វិកទី 2 និងក្រាហ្វិកទី 3)។ នៅក្នុងគ្រួសារ អតិថិជនជាស្ត្រី/ក្មេងស្រីតែងតែនិយាយអំពីបញ្ហាជម្លោះជាមួយគ្រួសារ ដែលកើតចេញពីភាពមិនចុះសម្រុងគ្នាទាក់ទងនឹងទំនាក់ទំនងជាមួយមិត្តប្រុស ឬដៃគូររបស់ពួកគេ និងការរៀបការដោយការផ្សំផ្គុំពីឪពុកម្តាយ។ នៅក្នុងស្ថានភាពខ្លះជនរួចពីរងគ្រោះមួយចំនួនធ្វើឲ្យខ្លួនឯងប្រឈមបញ្ហាអំពើហិង្សាក្នុងគ្រួសារ ដោយសារតែពួកគេជ្រើសរើសបន្តទំនាក់ទំនងស្នេហា ដោយគ្មានការយល់ព្រមពីគ្រួសារ (ពីគ្រួសាររបស់ខ្លួនផ្ទាល់ ឬគ្រួសាររបស់មិត្តប្រុស)។

ក្រាហ្វិកទី 2៖ ទំនាក់ទំនងរបស់ក្រុមបុរស/ក្មេងប្រុសជាមួយនឹងសមាជិកគ្រួសារ ឆ្នាំ2011 ដល់ឆ្នាំ2014



ក្រាហ្វិកទី 3៖ ទំនាក់ទំនងរបស់ក្រុមស្ត្រី/ក្មេងស្រីជាមួយសមាជិកគ្រួសារក្រៅពីប្ដី ឆ្នាំ2011ដល់ឆ្នាំ2014



### 3.1.2 ការរើសអើង

បញ្ហាដ៏ធ្ងន់ធ្ងរមួយ ដែលស្ត្រីរួចពីរងគ្រោះស្ទើរតែពាក់កណ្តាលបានជួបប្រទះ គឺការរើសអើងបន្ទាប់ពីធ្វើសមាហរណកម្មរួច ដែលយ៉ាងហោចណាស់ ពួកគេបានជួបប្រទះម្តងក្នុងអំឡុងពេលសិក្សាស្រាវជ្រាវនេះ។ ក្នុងអំឡុងពេលបួនឆ្នាំ ដែលបានដាក់បញ្ចូលក្នុងការសិក្សានេះ អតិថិជនរៀបរាប់ថា ពួកគេធ្លាប់ទទួលការរើសអើង ដោយសារបទពិសោធន៍ពីអតីតកាលរបស់ពួកគេ ចាប់ពីសំណាក់ប្តី ដៃគូរយៈពេលវែង និងសមាជិកគ្រួសាររបស់ពួកគេរហូតដល់ក្រុម ដែលមានវ័យស្របាលគ្នាជាមួយពួកគេ និងពីបណ្តាសំណាក់មនុស្សនៅក្នុងសង្គមទូទៅដូចជាគ្រូបង្រៀន និងអ្នកជិតខាងជាដើម។ អ្នកជិតខាង សិស្សរៀនជាមួយគ្នា និងគ្រួសារសាច់ថ្លៃក៏បានរើសអើង និងមាក់ងាយ ចំពោះអតិថិជនមួយចំនួនដោយសារតែភាពក្រីក្រ ឬដោយសារតែពួកគេមកពីគ្រួសារក្រីក្រ។ ជាក់ស្តែង អតិថិជនរៀននៅសាលាបានរៀបរាប់ប្រាប់ថា ពួកគេទទួលការរើសអើង និងបុរេនិច្ឆ័យថាជា "ក្មេងមណ្ឌល" ពីសំណាក់មិត្តភក្តិរួមថ្នាក់របស់ពួកគេ (ករណីនេះកើតឡើងចំពោះអតិថិជនក្នុងកម្មវិធីជំនួយស្នាក់នៅក្នុងមណ្ឌល និងអតិថិជនដែលធ្វើសមាហរកម្មរួច ដែលស្ថិតក្នុងការតាមដាន)។ អតិថិជនជាសិស្សម្នាក់បាននិយាយពីបទពិសោធន៍របស់នាងដោយបែបនេះថា៖

⇒ *មិត្តភក្តិនៅសាលារៀនធ្វើអោយខ្ញុំមិនសប្បាយចិត្តដោយសារពួកគេចូលចិត្តបង្អាប់ខ្ញុំ និងនិយាយពាក្យសម្តីអាក្រក់ដាក់ខ្ញុំ។ ខ្ញុំគិតថាពួកគេរើសអើងខ្ញុំដោយសារពួកគេដឹងថាខ្ញុំធ្លាប់ស្នាក់នៅមណ្ឌល។ ពួកគេនិយាយថា ក្មេងមណ្ឌល ជាក្មេងដែលត្រូវគេកេងប្រវ័ញ្ចផ្លូវភេទ និងចាប់រំលោភរហូតដល់មានកូនដោយមិនមានប្តី។ - ក្មេងស្រីរួចពីរងគ្រោះ អាយុ13ឆ្នាំ និយាយក្នុងឆ្នាំ2012។*

គួរចាប់អារម្មណ៍ថា ជនរួចពីរងគ្រោះជាបុរស/ក្មេងប្រុសមិនបានបង្ហាញពីការរើសអើងពីសំណាក់គ្រួសារ ឬសហគមន៍របស់ពួកគេ។ អតិថិជនជាបុរស/ក្មេងប្រុសភាគច្រើនបានរៀបរាប់ពីបទពិសោធន៍ល្អៗ ដែលពួកគេមានជាមួយអ្នកជិតខាង និងមិត្តភក្តិរួមការងារនៅក្នុងសហគមន៍បន្ទាប់ពីពួកគេបានធ្វើសមាហរណកម្ម។ អតិថិជនមួយចំនួនបានរៀបរាប់ពីជម្លោះ/បញ្ហាជាមួយនឹងអ្នកគ្រប់គ្រងនៅកន្លែងធ្វើការ និងការវាយគ្នាជាមួយអ្នកជិតខាងរបស់ពួកគេផងដែរ (ក្រាហ្វិកទី4) ប៉ុន្តែពួកគេមិនបានគិតថាបញ្ហាទាំងអស់នេះជាការមាក់ងាយ ឬការរើសអើងនោះទេ។ ដោយសារការសិក្សានេះមានចំនួនសំណាកជាបុរស/ក្មេងប្រុសមានកម្រិត គឺមានទំហំសំណាកតូច (១៥នាក់)។ ហេតុដូច្នេះហើយ ចំពោះការសិក្សានៅពេល

អនាគតគួរតែគិតពិចារណាក្នុងការកំណត់ពីទំហំ ឬក៏វិសាលភាពនៃការរើសអើងក្នុងសហគមន៍ចំពោះជនរួចពីរងគ្រោះជាបុរស/ក្មេងប្រុស។

ជនរួចពីរងគ្រោះជាស្ត្រី/ក្មេងស្រី បានបង្ហាញពីបទពិសោធន៍របស់ពួកគេនៅក្នុងសហគមន៍ជាមួយអ្នកជិតខាង មិត្តភក្តិ និងអ្នករួមការងាររបស់ពួកគេ ទាំងបទពិសោធន៍វិជ្ជមាន និងអវិជ្ជមាន (ក្រាហ្វិកទី 5)។ បន្ទាប់ពីធ្វើសមាហរណកម្មរួច ជនរួចពីរងគ្រោះមួយចំនួនបាននិយាយពីពេលវេលា ដែលពួកគេចំណាយដើម្បីបង្កើតមិត្តភក្តិ និងកសាងទំនាក់ទំនងដែលចេះជួយគ្នាទៅវិញទៅមកក្នុងសហគមន៍។ អ្នកខ្លះបាននិយាយពីម្ចាស់ផ្ទះជួលមានចិត្តល្អ និងការគាំទ្រពីសំណាក់អ្នកដឹកនាំនៅក្នុងឃុំសង្កាត់របស់ពួកគេ។ ស្របពេលជាមួយគ្នានោះដែរ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ អតិថិជនមួយចំនួននៅតែព្យាយាមរក្សាការសម្ងាត់ពីអតីតកាលរបស់ពួកគេដដែលពីមិត្តភក្តិរួមការងារ អ្នកជិតខាង និងសូម្បីតែប្តី និងគ្រួសាររបស់ពួកគេ។ អតិថិជនស្ថិតក្នុងក្រុមវ័យចំណាស់និយាយរៀបរាប់ពីជម្លោះ និងការរើសអើងនៅក្នុង សហគមន៍ពីសំណាក់អ្នកជិតខាង និងអ្នករួមការងារដែលបានកើតឡើងម្តងហើយម្តងទៀតអស់ជាច្រើនឆ្នាំ។ ការផ្លាស់ប្តូរទីកន្លែងរស់នៅ និងការងាររបស់អតិថិជនមួយចំនួន ជាធម្មតាមិនបានធ្វើឲ្យស្ថានភាពល្អប្រសើរវិញឡើយ។ វាមើលទៅហាក់ដូចជាវាបានចងអតិថិជនទាំងនោះនៅក្នុងវដ្តនៃជម្លោះ ដែលតែងតែកើតឡើងជាមួយនឹងអ្នកជិតខាង និងអ្នករួមការងាររបស់ពួកគេនៅគ្រប់កន្លែងដែលពួកគេបានទៅដល់។ ជនរួចពីរងគ្រោះវ័យកណ្តាលម្នាក់ បានចែករំលែកបទពិសោធន៍ទាក់ទងនឹងការរើសអើងនៅក្នុងសហគមន៍ពីសំណាក់មិត្តរួមការងារតាមបែបដូចខាងក្រោម៖

⇒ *ពួកគេចាប់ផ្តើមឈប់និយាយរកខ្ញុំនៅពេលពួកគេបានដឹងពីអតីតកាលរបស់ខ្ញុំ។ ពួកគេយល់ច្រឡំលើខ្ញុំ ហើយពួកគេលែងចាត់ទុកខ្ញុំជាមនុស្សល្អទៀតហើយ។ ពួកគេបាននិយាយរឿងរបស់ខ្ញុំទៅប្រាប់អ្នកទើបចូលធ្វើការថ្មី។ - ស្ត្រីរួចពីរងគ្រោះ អាយុ27ឆ្នាំ និយាយក្នុងឆ្នាំ2012*

របាយការណ៍មួយចំនួនបានសិក្សាពីសារៈសំខាន់នៃបរិយាកាសសហគមន៍ ក្នុងការទទួលយកជនរួចពីរងគ្រោះ ដែលធ្វើសមាហរណកម្មត្រលប់ទៅសហគមន៍វិញ (Crawford and Kaufman 2008; Yntiso et al. 2009; Surtees 2012; Muco 2013)។ ទោះបីជាអតិថិជនជាច្រើននៅក្នុងការសិក្សានេះ បាននិយាយអំពីបទពិសោធន៍ ដែលបានត្រូវគេរើសអើងក៏ដោយ ក៏នៅមានអតិថិជនមួយចំនួនផ្សេងទៀតមិនធ្លាប់មានបទពិសោធន៍រើសអើងនេះដែរ។ ខណៈពេលជាមួយគ្នានេះដែរ អតិថិជនភាគច្រើនបានបង្ហាញថា ពួកគេបានរក្សារឿងអតីតកាលរបស់ពួកគេជាអាថ៌កំបាំងពីសំណាក់អ្នករួមការងារ អ្នកជិតខាង និងពីស្វាមី និងគ្រួសាររបស់ពួកគេផងដែរ (ជាពិសេស អតិថិជនដែលនៅក្នុងក្រុមស្ត្រី/ក្មេងស្រី ដែលបានធ្វើ

សមាហរណកម្មរួច)។ ការសិក្សាស្រាវជ្រាវនេះមិនអាចកំណត់បានថាតើកម្រិត ដែលអ្នកជិតខាង និងគ្រួសាររបស់អតិថិជនដឹង ឬក៏មិនដឹងអំពីសាវតាររបស់ពួកគេកម្រិតណានោះទេ ហើយក៏ដូចគ្នាជាមួយនឹងកម្រិតនៃការគាំទ្រ និងការទទួលស្គាល់ ដែលពួកគេទទួលបានពីស្វាមី និងគ្រួសាររបស់ពួកគេដែរ ព្រោះវាហួសពីទំហំនៃការសិក្សានេះ។

ក្រាហ្វិកទី 4៖ បទពិសោធន៍អតិថិជនជាបុរស/ក្មេងប្រុស ដែលធ្វើសមាហរកម្មរួចក្នុងសហគមន៍ ឆ្នាំ2011-2014



ក្រាហ្វិកទី 5៖ បទពិសោធន៍អតិថិជនជាស្ត្រី/ក្មេងស្រីដែលធ្វើសមាហរកម្មរួចក្នុងសហគមន៍ ឆ្នាំ2011-2014



### 3.1.3 កត្តារុញច្រាន[1]

កត្តារុញច្រាននៅក្នុងសិក្សានេះ ត្រូវបានធ្វើការប៉ាន់ប្រមាណដោយសារកត្តាទាំងអស់នោះមានការទាក់ទងនឹងការធ្វើសេចក្តីសម្រេចចិត្ត និងបទពិសោធន៍ជីវិតរបស់ជនរួចពីរងគ្រោះ ទៅលើការចាប់ផ្តើម និងការឈប់ពីកម្មវិធីវគ្គបណ្តុះបណ្តាលការងារ ការចាប់ផ្តើមធ្វើការ និងឈប់ធ្វើការ ការផ្លាស់ប្តូរទីកន្លែងនៅក្នុងប្រទេសកម្ពុជា និងការធ្វើចំណាកស្រុកទៅប្រទេសដទៃដើម្បីស្វែងរកឱកាសការងារប្រសើរជាងមុន ការបង្កើតគ្រួសារ និងការបង្កើតគ្រួសារថ្មីម្តងទៀតជាដើម។ ជាញឹកញាប់ អតិថិជននិយាយរៀបរាប់ពីការសម្រេចចិត្តជាច្រើន និងករណីផ្លាស់ប្តូរទីកន្លែងជាច្រើនដងច្រើនសារ អំឡុងពេលប៉ុន្មានឆ្នាំកន្លងមកក្នុងការសិក្សានេះ។ ជនរួចពីរងគ្រោះបានបង្ហាញនូវប្រធានបទបញ្ហារួមធំៗចំនួន13ចំនុច ដែលដើរតួជាកត្តារុញ និងកត្តាច្រានក្នុងជីវិតរបស់ពួកគេ។ អតិថិជនជាញឹកញាប់និយាយអំពីបញ្ហាបំណុល ប្រាក់ចំណូលមិនគ្រប់គ្រាន់ និងកាតព្វកិច្ចត្រូវផ្គត់ផ្គង់គ្រួសារ។ អតិថិជនក្នុងមណ្ឌលមិនសូវបាននិយាយពីប្រធានបទរួមចំនួនប្រាំចំនុច ដែលចំនុចទាំងនេះក្លាយជាប្រធានបទរួមសំខាន់សម្រាប់អតិថិជនភាគច្រើន ដែលបានធ្វើសមាហរណកម្មរួច (ប្រធានបទរួមទាំងប្រាំនោះរួមមាន៖ បញ្ហាគ្មានការងារធ្វើ បញ្ហាសុខភាពគ្រួសារ ការមានផ្ទៃពោះ ការរើសអើងមាក់ងាយក្នុងសហគមន៍ និងឱកាសទទួលបានការងារ ដែលសមរម្យជាងមុន)។

### 3.1.4 ឱកាសការងារ និងការរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ

ការព្យាយាមស្វែងរកឱកាសលើកកម្ពស់កម្រិតជីវភាព គឺជាកត្តាជំរុញមួយដ៏សំខាន់ និងក៏ជាក្តីបារម្ភមួយដែលតែងតែកើតមានសម្រាប់ជនរួចពីរងគ្រោះ និងគ្រួសាររបស់ពួកគេ។ ការសិក្សានេះបង្ហាញថា មានគ្រួសារអតិថិជនភាគច្រើនមានការលំបាក នៅក្នុងការរកប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ការរស់នៅ(ក្រាហ្វិកទី6)។ គ្រួសារមួយចំនួនបានធ្វើចំណាកស្រុកទៅប្រទេសថៃដើម្បីស្វែងរកការងារធ្វើ។ ជនរួចពីរងគ្រោះជាបុរស/ក្មេងប្រុសភាគច្រើនមានក្តីបារម្ភពីបញ្ហាថវិការ (លុយ) ហើយអ្នកខ្លះទៀតនិយាយពីអារម្មណ៍ឯកា និងការបោះបង់នៅពេលដែលម្តាយរបស់ពួកគេចាកចេញពីពួកគេទៅដើម្បីស្វែងរកការងារធ្វើនៅប្រទេសថៃ (ក្រាហ្វិកទី 7)។ ជនរួចពីរងគ្រោះម្នាក់បាននិយាយថា៖

---

[1] កត្តារុញច្រានទាំងឡាយ គឺជាប្រធានបទរួម ដែលកើតឡើងជារឿយៗ ដែលជាសកម្មភាពដើម្បីជំរុញមនុស្សឱ្យទៅឆ្ងាយពី(កត្តាជំរុញ)លំនៅដ្ឋាន និង/ឬការងារ និងទាក់ទាញមនុស្ស(កត្តាច្រាន)ឱ្យទៅរកលំនៅដ្ឋាន និង/ឬកន្លែងការងារថ្មី។ សម្រាប់ពត៌មានបន្ថែម សូមមើលទៅផ្នែកទី៤.៤ នៃរបាយការណ៍សិក្សាលើប្រធានបទរួម។

⇒ *ប្រសិនបើមិនយកខ្ញុំទៅថៃជាមួយទេ ខ្ញុំនឹងឈប់ញុំាបាយ ហើយឈប់ទៅសាលារៀនទៀត។ ខ្ញុំនឹងគិតតែជិះកង់ដើរលេង ហើយនឹងព្យាយាមបង្កបញ្ហា។ ខ្ញុំចង់រស់នៅជាមួយម្តាយរបស់ខ្ញុំ។ -ក្មេងប្រុសរួចពីរងគ្រោះ អាយុ14ឆ្នាំ និយាយក្នុងឆ្នាំ2014។*

ជនរួចពីរងគ្រោះមួយចំនួនតូច បាននិយាយពីភាពប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ។ ជនរួចពីរងគ្រោះភាគច្រើន ដែលមានប្រាក់ចំណូលសមរម្យក៏បាននិយាយពីចំណុចនេះដែរ ដោយសារនៅក្នុងគ្រួសាររបស់គេមានសមាជិកច្រើនជាងមួយនាក់ជួយរកប្រាក់សម្រាប់ ផ្គត់ផ្គង់គ្រួសារ។ អតិថិជនដែលបានបញ្ជាក់ថា ពួកគេមានប្រាក់ចំណូលគ្រប់គ្រាន់អាចផ្គត់ផ្គង់តាមតម្រូវការគ្រួសាររបស់ពួកគេបានភាគច្រើនគឺជាអតិថិជនដែលធ្វើការជាមួយអង្គការ។ ការងារផ្នែកសម្អាតនៅក្នុងវិស័យបដិសណ្ឋារកិច្ច និងអ្នកគ្រប់គ្រងនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ គឺជាមុខតំណែងពីរនៅក្នុងវិស័យឧស្សាកម្មឯកជនដែលជនរួចពីរងគ្រោះកំពុងធ្វើការងារនៅទីនោះយ៉ាងរលូន និងទទួលបានប្រាក់ចំណូលសមរម្យសម្រាប់គ្រួសាររបស់ពួកគេ។ អតិថិជនម្នាក់បាននិយាយរៀបរាប់ពីការងាររបស់នាងនៅក្នុងវិស័យរោងចក្រក្នុងឆ្នាំ2013 និងឆ្នាំ2014៖

⇒ *ខ្ញុំបានធ្វើការនៅក្នុងរោងចក្រនេះ ប្រហែលជា6ខែហើយ។ ខ្ញុំទទួលបានប្រាក់ខែ130ដុល្លារក្នុងមួយខែ ហើយខ្ញុំគិតថាប្រាក់ខែរបស់ខ្ញុំគឺគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំថ្ងៃរបស់ខ្ញុំ។ - ស្ត្រីជនរួចពីរងគ្រោះ អាយុ21ឆ្នាំ បាននិយាយក្នុងឆ្នាំ2013។*

⇒ *នៅកន្លែងធ្វើការរបស់ខ្ញុំ គេបានតំឡើងតំណែងឲ្យខ្ញុំធ្វើជាប្រធានក្រុម។ ប្រាក់ខែរបស់ខ្ញុំក៏បានតំឡើងឡើងដែរ។ - ស្ត្រីរួចពីរងគ្រោះ អាយុ22ឆ្នាំ និយាយក្នុងឆ្នាំ2014។*

ក្រាហ្វិកទី 6 ៖ ការរកប្រាក់ផ្គត់ផ្គង់គ្រួសារបន្ទាប់ពីធ្វើសមាហរណកម្មរបស់ក្រុមស្ត្រី/ក្មេងស្រី ឆ្នាំ 2011-2014



ក្រាហ្វិកទី 7៖ ការរកប្រាក់ផ្គត់ផ្គង់គ្រួសារបន្ទាប់ពីធ្វើសមាហរណកម្មរបស់ក្រុមបុរស/ក្មេងប្រុស ឆ្នាំ 2011-2014




សេចក្តីលំអិតនៃការសិក្សានេះ ទាក់ទងនឹងឧបសគ្គ និងបញ្ហាប្រឈមនានារបស់ជនរួចពីរងគ្រោះជុំវិញបញ្ហាបំណុល ការងារធ្វើ និងវគ្គបណ្តុះបណ្តាល ឬការអប់រំនានា គឺមិនស្ថិតនៅក្នុងទំហំនៃរបាយការណ៍សិក្សាលើប្រធានបទរួមនេះទេ។ យ៉ាងណាមិញ ការសិក្សានេះបង្ហាញពីឧបសគ្គមួយចំនួន ដែលជនរួចពីរងគ្រោះជួបប្រទះពេលធ្វើសមាហរណកម្មត្រលប់ទៅសហគមន៍វិញ។ ឱកាសការងារ និងប្រាក់ចំណូលសមរម្យ គឺជាកត្តាសំខាន់ចម្បងនៅក្នុងគ្រួសារ ហើយវាក៏ជាក្តីបារម្ភមួយ ដែលតែងតែកើតឡើងចំពោះជនរួចពីរងគ្រោះ និងគ្រួសាររបស់ពួកគេភាគច្រើន។ បំណុលបានធ្វើឲ្យអតិថិជនភាគច្រើនមានភាពតានតឹងស្មុគស្មាញ ជាពិសេសប្រសិនពួកគេជាសមាជិកគ្រួសារតែម្នាក់ ដែលរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារទាំងមូល។ អតិថិជននៅក្នុងការសិក្សានេះភាគច្រើនបានឈប់ពីកម្មវិធីបណ្តុះបណ្តាលដើម្បីទៅរកប្រាក់ផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។ ជំនួសដោយការទៅសាលារៀន ជនរួចពីរងគ្រោះដែល

មានអាយុក្នុងវ័យសិក្សាមួយចំនួនបានស្វែងរកការងារធ្វើ ដើម្បីចូលរួមចំណែកផ្គត់ផ្គង់គ្រួសាររបស់គេតាមរបៀបមួយសមរម្យ។ កម្មវិធីសមាហរណកម្មភាគច្រើនបានព្យាយាមក្នុងការដោះស្រាយនូវក្ដីបារម្ភ និងបញ្ហាទាំងនេះតាមរយៈការរៀបចំកម្មវិធីជំនួយផ្នែកការសិក្សា ស្វែងរកការងារធ្វើ អាជីវកម្មខ្នាតតូច អាជីពការងារសង្គម និងសេវាតាមដានសមាហរណកម្មផ្សេងៗទៀតជាដើម។ គម្រោងសិក្សាស្រាវជ្រាវមេអំបៅរយៈពេលវែងបានផ្ដល់ទិន្នន័យយ៉ាងទូលំទូលាយទៅដល់កម្មវិធីរបស់អង្គការនានា (NGOs) តែយ៉ាងណាមិញ សម្រាប់ការសិក្សានៅពេលអនាគត ចំពោះទិន្នន័យបែបនេះ យើងផ្ដល់អនុសាសន៍ធ្វើយ៉ាងណាត្រូវបញ្ជាក់ឲ្យកាន់តែច្បាស់ពីចំនុចខ្លាំង ឧបសគ្គប្រឈម និងបញ្ហានានារបស់ជនរួចពីរងគ្រោះជុំវិញបញ្ហាពាក់ព័ន្ធដូចជាបំណុល បញ្ហាការងារធ្វើ និងវត្ថុបណ្ដុះបណ្ដាល ឬការអប់រំជាដើម។

### 3.1.5 ការបង្ហាញអំពីសុខុមាលភាព

អតិថិជនទាំងពីរក្រុម (ទាំងអ្នករស់នៅក្នុងមណ្ឌល និងអ្នកដែលបានធ្វើសមាហរណកម្មរួច) បានបង្ហាញពីអារម្មណ៍ពេញចិត្ត និងសប្បាយរីករាយនឹងអ្វី ដែលពួកគេមាននៅក្នុងជីវិត។ អតិថិជនក៏បានបង្ហាញពីការព្រួយបារម្ភនៅក្នុងជីវិតរបស់ពួកគេដែរ ខណៈពេលដែលពួកគេកំពុងរស់នៅក្នុងមណ្ឌល និងបន្ទាប់ពីបានធ្វើសមាហរណកម្មត្រលប់ទៅសហគមន៍វិញ។ បញ្ហាការព្រួយបារម្ភផ្សេងៗនៅពេលស្នាក់ក្នុងមណ្ឌលរួមមាន៖ ការព្រួយបារម្ភពីសមាជិកគ្រួសារដែលមានជម្ងឺ ឬបញ្ហាការខ្វះខាតម្ហូបអាហានៅផ្ទះ ការព្រួយបារម្ភពីការធ្វើសមាហរណកម្ម និងការប្រឈមជាមួយនឹងបញ្ហាលំបាកៗមួយចំនួនដែលអាចកើតឡើងក្រោយពេលពួកគេត្រលប់ទៅផ្ទះ ការបារម្ភទាក់ទងនឹងការសិក្សារៀនសូត្រ និង/ឬបញ្ហារឿងក្ដីនៅតុលាការទាក់ទងនឹងករណីរបស់ពួកគេជាដើម ជាពិសេសប្រសិនបើរឿងក្ដីនោះមានជាប់ទាក់ទងនឹងសមាជិកគ្រួសាររបស់ពួកគេ។ ចំពោះអ្នកដែលបានធ្វើសមាហរណកម្មរួច ភាគច្រើនតែងមានការព្រួយបារម្ភចំពោះការរក្សាតុល្យភាពក្នុងជីវិត ព្រោះវាទាក់ទងនឹងបញ្ហាជម្ងឺ បំណុល ការស្វែងរកប្រាក់ចំណូលអោយបានគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ការរស់នៅ បញ្ហាគ្មានប្រាក់ចំណូលក្នុងពេលកំពុងរៀនសូត្រ ឬទទួលវគ្គបណ្ដុះបណ្ដាល បញ្ហាគ្មានការងារធ្វើ និងការមានកូនជាដើម។ អតិថិជនភាគច្រើនបានបង្ហាញថា ពួកគេមានជីវិតរស់នៅល្អក្នុងមណ្ឌល ជាពិសេសក្រុមអតិថិជនជាស្ត្រី/ក្មេងស្រី ដែលមានអាយុក្មេងជាងគេបំផុតក្នុងការសិក្សានេះ ដែលពួកគេកំពុងរស់នៅក្នុងមណ្ឌល។ ពួកគេភាគច្រើននិយាយអំពីសេចក្ដីស្រលាញ់ ដែលពួកគេបានទទួលពីបុគ្គលិកមណ្ឌល និងម្ដាយថែរក្សា ក៏ដូចគ្នានឹងភាពសុខស្រួល និងសុវត្ថិភាពដែលមណ្ឌលផ្ដល់អោយដូចជា អាហារបរិភោគគ្រប់គ្រាន់ ថ្នាំពេទ្យ/ការព្យាបាល និងទីកន្លែង

រស់នៅល្អស្អាត។ បន្ទាប់ពីធ្វើសមាហរណកម្មរួច ជនរួចពីរងគ្រោះជាច្រើននិយាយថា ជីវិតរស់នៅខាងក្រៅមណ្ឌលមានការលំបាកច្រើនជាងនៅក្នុងមណ្ឌល។

ការសិក្សានេះ បានធ្វើការវិភាគដោយផ្អែកលើប្រធានបទរួមបីសំខាន់ៗ៖ ប្រាក់ចំណូលមិនសមរម្យ ទំនាក់ទំនងគ្រួសារមិនល្អ (សម្រាប់តែអ្នក ដែលមានទំនាក់ទំនងគ្រួសារមិនល្អប៉ុណ្ណោះ) និងបញ្ហាការរើសអើងក្នុងសហគមន៍ ដោយយោងទៅតាមការបង្ហាញរបស់ជនរួចពីរងគ្រោះអំពីអារម្មណ៍សប្បាយចិត្ត និងពេញចិត្តជាមួយនឹងអ្វី ដែលមានក្នុងសហគមន៍។ ការវិភាគនេះទទួលបានពីអតិថិជនចំនួន77នាក់ ដែលបានធ្វើសមាហរណកម្មត្រលប់ទៅសហគមន៍រួចហើយ គិតចាប់តាំងពីឆ្នាំទី1 រហូតដល់ឆ្នាំទី4នៃការសិក្សានេះ។ លទ្ធផលនេះបានបង្ហាញឲ្យឃើញថា មានតែពីរករណីប៉ុណ្ណោះដែលជនរួចពីរងគ្រោះបានបង្ហាញពីអារម្មណ៍សប្បាយចិត្ត និងអារម្មណ៍ពេញចិត្តជាមួយនឹងការរស់នៅក្នុងសហគមន៍ ខណៈដែលពួកគេកំពុងជួបប្រទះការលំបាកក្នុងការរកប្រាក់ចំណូល ហើយមានតែបួនករណីប៉ុណ្ណោះ ដែលអតិថិជនបង្ហាញពីអារម្មណ៍សប្បាយរីករាយ ទោះបីជាពួកគេជួបប្រទះនូវបទពិសោធន៍ការរើសអើង។ គ្មានអតិថិជនណាមួយបង្ហាញពីអារម្មណ៍ពេញចិត្ត និងសប្បាយចិត្តទេ នៅពេលដែលពួកគេមានទំនាក់ទំនងគ្រួសារមិនល្អនៅក្នុងជីវិតរបស់ពួកគេ។ លទ្ធផលនេះបង្ហាញថា បញ្ហាទាំងបីនេះបានដើរតួយ៉ាងសំខាន់ក្នុងការកំណត់ពីសុខុមាលភាព និងភាពឆាប់ត្រលប់មកធម្មតាវិញ របស់ជនរួចពីរងគ្រោះនៅក្នុងសហគមន៍។ ជនរួចពីរងគ្រោះម្នាក់បាននិយាយអំពីការលំបាកដែលនាងបានជួបប្រទះជាមួយនឹងប្តីធ្វើបាប រំលោភបំពាន និងការមិនមានទំនាក់ទំនងគ្រួសារល្អផ្សេងៗទៀតនៅក្នុងជីវិតរបស់នាងក្នុងរយៈពេលបីឆ្នាំ៖

⇒ *ខ្ញុំមិនដែលមានអារម្មណ៍សប្បាយចិត្ត ឬមានសុភមង្គលម្តងណាទេ តាំងពីខ្ញុំបានរៀបការជាមួយប្តីខ្ញុំ។ គាត់មិនដែលឲ្យលុយខ្ញុំសម្រាប់ផ្គត់ផ្គង់គ្រួសារទេ។ ខ្ញុំត្រូវតែដើររកបេះបន្លែនៅជុំវិញផ្ទះសម្រាប់ធ្វើម្ហូប...ខ្ញុំចង់បែកពីប្តីរបស់ខ្ញុំ និងយកកូនខ្ញុំទៅជាមួយ ប៉ុន្តែប្តីខ្ញុំ និងគ្រួសារគាត់បាននិយាយថា ខ្ញុំអាចចេញទៅបាន តែខ្ញុំមិនអាចយកកូនខ្ញុំទៅជាមួយទេ។ ខ្ញុំត្រូវទុកកូននៅជាមួយពួកគេ។ - ស្ត្រីរួចពីរងគ្រោះ អាយុ20ឆ្នាំ និយាយក្នុងឆ្នាំ2014។*

លទ្ធផលសិក្សាបានបង្ហាញថា ប្រធានបទរួមទាំងបីនេះបានដើរតួយ៉ាងសំខាន់នៅក្នុងការកំណត់ពីអារម្មណ៍ពេញចិត្ត និងសប្បាយរីករាយរបស់ជនរួចពីរងគ្រោះនៅក្នុងសហគមន៍។

## 3.2 ការសិក្សាស្រាវជ្រាវរយៈពេលវែង

ការសិក្សាស្រាវជ្រាវរយៈពេលវែងនេះ ធ្វើការតាមដានអតិថិជនតាមរយៈព្រឹត្តិការណ៍សំខាន់ៗ ហើយនិងការប្រែប្រួលមួយចំនួននៅក្នុងជីវិតជនរួចពីរងគ្រោះ។ ទោះបីជាទិន្នន័យនៅក្នុងការសិក្សានេះមានរយៈពេលត្រឹមតែបួនឆ្នាំដំបូងក៏ដោយ ក៏អតិថិជនស្ទើរតែទាំងអស់នឹងឈានដល់អាយុពេញវ័យ នៅពេលដែលគម្រោងនេះបញ្ចប់ក្នុងរយៈពេលសិក្សាដប់ឆ្នាំរបស់ខ្លួន ហើយការប្រែប្រួលផ្សេងៗទៀតក៏នឹងកើតឡើងដែរ។ អតិថិជនសរុបចំនួន 49នាក់ បានធ្វើសមាហរណកម្មពីកម្មវិធីមណ្ឌល និងការស្នាក់នៅក្នុងផ្ទះបណ្តោះអាសន្ន បានត្រលប់ទៅសហគមន៍វិញក្នុងអំឡុងពេលសិក្សានេះ។ ជនរួចពីរងគ្រោះបានត្រលប់ទៅចូលសាលាសារជាថ្មី ឬចាប់ផ្តើមទទួលវគ្គបណ្តុះបណ្តាលការងារវិជ្ជាជីវៈ និងឈប់ ឬបញ្ចប់ការសិក្សាពីសាលា និងកម្មវិធីបណ្តុះបណ្តាល និងការងារជាមួយអង្គការ ដើម្បីទៅស្វែងរកការងារនៅក្នុងសហគមន៍របស់ពួកគេ។ ការវិវត្តនៃភាពចាស់ទុំ និងការធ្វើការសម្រេចចិត្តទាក់ទងនឹងគោលដៅ និងទំនាក់ទំនងក្នុងជីវិត និងការរៀនរស់នៅដោយឯករាជ្យ សុទ្ធតែជាប្រធានបទដែលត្រូវបានជនរួចពីរងគ្រោះលើកមកពិភាក្សា នៅពេលពួកគេឆ្លងកាត់អន្តរកាលនេះ។

អាពាហ៍ពិពាហ៍ គឺជាព្រឹត្តិការណ៍សង្គមដ៏សំខាន់មួយ ដែលអតិថិជនភាគច្រើនមិនទាន់បានឆ្លងកាត់នៅឡើយ។ នៅក្នុងការសិក្សានេះមានអតិថិជនភាគច្រើន ជាអ្នកនៅលីវ គឺប្រហែលជា 90នាក់ ក្នុងចំណោមអតិថិជនទាំងអស់ចំនួន 109នាក់ ដែលបានចូលរួមក្នុងការសិក្សាឆ្នាំ 2014នេះ។ នៅពេលយើងសាកសួរពួកគេ អតិថិជនស្ទើរតែទាំងអស់បានសម្តែងអារម្មណ៍ថា នៅថ្ងៃអនាគត ពួកគេមានបំណងចង់បានប្តី ដែលស្មោះត្រង់ ចេះជួយយកអាសារគ្នា និងចង់ចាប់ផ្តើមគ្រួសារជាមួយគ្នា។ យ៉ាងណាមិញ ស្ថានភាពអន្តរកាលនេះ គឺជាដំណើរមួយដ៏លំបាកសម្រាប់ជីវិតជនរួចពីរងគ្រោះភាគច្រើនឆ្លងកាត់ ព្រោះពួកគេត្រូវប្រឈមនឹងបញ្ហានៃការមាក់ងាយពីសង្គម ការបំពេញតាមការរំពឹងទុករបស់គ្រួសារ និងផ្សារភ្ជាប់នូវទស្សនៈ ដែលខុសគ្នាពីមួយជំនាន់ទៅមួយជំនាន់ ដែលសុទ្ធសឹងតែជាបញ្ហាដែលធ្វើឲ្យមានភាពស្មុគស្មាញកាន់តែខ្លាំង។ សមត្ថភាពនៅក្នុងការបណ្តុះនូវទំនាក់ទំនងជាមួយគូរស្រករ ដែលអាចផ្តល់ការគាំទ្រ និងលើកទឹកចិត្តរបស់ជនរួចពីរងគ្រោះទាំងនេះ អាចបញ្ជាក់ឲ្យឃើញថា តើការសម្រេចចិត្តនានាជាច្រើនក្នុងការជ្រើសរើសគូស្រករនេះ អាចក្លាយជាចំនុចឡើងចុះសំខាន់ៗជាវិជ្ជមាន ឬអវិជ្ជមានក្នុងជីវិតរបស់ពួកគេនៅពេលខាងមុខ។

### 3.2.1 ចំណុចឡើងចុះវិជ្ជមាន និងអវិជ្ជមានសំខាន់ៗ

Werner (1993)បានពិភាក្សាអំពីសារៈសំខាន់នៃ *"ចំណុចឡើងចុះចម្បងៗ"* ដែលកើតឡើងនៅក្នុងជីវិតរបស់មនុស្សទើបចូលវ័យកណ្តាល ដែលជះឥទ្ធិពលទៅលើភាពឆាប់ត្រលប់មកធម្មតាវិញ។ អ្នកនិពន្ធបានពិភាក្សាពីតួនាទីនៃការអប់រំ និងការចូលរួមយ៉ាងសកម្មជាមួយក្រុមជំនុំ ឬក៏ជាមួយនឹងសាសនាណាមួយនៅក្នុងសហគមន៍ ដែលអាចភ្ជាប់ទំនាក់ទំនងកុមារ ឬមនុស្សទើបចូលវ័យកណ្តាល ហើយដែលស្ថិតក្នុងហានិភ័យ ទៅនឹងឱកាសដែលពួកគេអាចកែប្រែជីវិតរបស់ពួកគេឲ្យបានល្អឡើងវិញដូចជា ការមានការងារធ្វើដែលមានប្រាក់កម្រៃខ្ពស់ និងមានទំនាក់ទំនងដែលចេះគាំទ្រគ្នាទៅវិញទៅមក។ ស្រដៀងគ្នានេះដែរ ការសិក្សាស្រាវជ្រាវលើប្រធានបទរួមនេះបានកំណត់ពីចំណុចឡើងចុះជាវិជ្ជមាន និងអវិជ្ជមានសំខាន់ៗមួយចំនួននៅក្នុងជីវិតសមាហរណកម្មរបស់ជនរួចពីរងគ្រោះ។

ឯកសារយោងបង្ហាញយ៉ាងច្បាស់ថា ទំនាក់ទំនងដែលចេះលើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមកប្រហែលជាមានសក្តានុពលយ៉ាងខ្លាំងបំផុត ក្នុងការជះឥទ្ធិពលទៅលើភាពឆាប់ត្រលប់មកធម្មតាវិញក្នុងចំណោមជនរួចពីរងគ្រោះ (Nowak-Carter 2012; Noltemeyer and Bush 2013)។ នៅពេលយើងបានធ្វើការសាកសួរ ជនរួចពីរងគ្រោះជាស្ត្រី/ក្មេងស្រីស្ទើរតែទាំងអស់ នៅក្នុងការសិក្សានេះបង្ហាញថាពួកគេមានបំណងចង់រៀបការជាមួយនឹងស្វាមី ដែលស្មោះត្រង់ និងចេះគាំទ្រគ្នា ហើយចាប់ផ្តើមគ្រួសារមួយជាមួយគេ។ យ៉ាងណាមិញ អតិថិជនភាគច្រើននៅក្នុងការសិក្សានេះ គឺជាអ្នកនៅលីវនៅឡើយដែលមានចំនួនប្រហែលជា 90នាក់ ក្នុងចំណោមអ្នកចូលរួមនៅក្នុងរបាយការណ៍នេះ109នាក់។ យោងតាមការសិក្សាស្រាវជ្រាវក្នុងឆ្នាំ2013 មួយឆ្នាំពេញ យើងឃើញថាមាន 50% (ស្មើនឹង14នាក់) នៃស្ត្រី/ក្មេងស្រីនៅក្នុងក្រុមអតិថិជន ដែលធ្វើសមាហរណកម្មរួចបានរៀបការ ឬមានដៃគូររយៈពេលវែង។ យ៉ាងណាមិញ នៅក្នុងចំណោមស្ត្រី/ក្មេងស្រីនៅក្នុងកម្មវិធីមណ្ឌល ហើយបានធ្វើសមាហរណកម្មរួចមានតែ15% (ស្មើនឹង5នាក់) បានរៀបការ ឬមានដៃគូរ។ គ្មានអតិថិជនជាបុរស/ក្មេងប្រុសក្នុងកម្មវិធីមណ្ឌល ហើយបានធ្វើសមាហរណកម្មរួច បានរៀបការ ឬមានដៃគូរទេ។ សមត្ថភាពក្នុងការបង្កើតនូវទំនាក់ទំនងជាមួយគូរស្រករ ដែលចេះផ្តល់ការគាំទ្រ និងលើកទឹកចិត្តរបស់ជនរួចពីរងគ្រោះទាំងនេះអាចបញ្ជាក់ឲ្យយើងឃើញថា តើការសម្រេចចិត្តនានាជាច្រើនក្នុងការជ្រើសរើសគូរស្រករនេះ អាចក្លាយជាចំនុចឡើងចុះសំខាន់ៗជាវិជ្ជមាន ឬអវិជ្ជមាននៅក្នុងជីវិតរបស់ពួកគេ។

ដូចបានពិភាក្សាខាងលើ ទំនាក់ទំនងរបស់ជនរួចពីរងគ្រោះជាមួយនឹងដៃគូរ និងប្តីប្រពន្ធរបស់ពួកគេភាគច្រើនកើតឡើងជាចំណុចឡើងចុះអវិជ្ជមាននៅក្នុងជីវិតរបស់ជនរួចពីរងគ្រោះ។ សេចក្តីសន្និដ្ឋាន

នេះ បានធ្វើឡើងដោយផ្តែកជាចម្បងទៅលើក្រុមអតិថិជនក្នុងការសិក្សា ដែលមានអាយុចាស់ជាងគេបំផុត។ យ៉ាងណាមិញ អតិថិជនក្នុងក្រុមនេះមិនដែលបានស្នាក់នៅក្នុងមណ្ឌល ហើយភាគច្រើនពួកគេជាមនុស្សវ័យកណ្តាល និងមនុស្សទើបចូលវ័យកណ្តាល។ ដំណើរការធ្វើសមាហរណកម្មរបស់អតិថិជននៅក្រុមស្រ្តី ដែលបានធ្វើសមាហរណកម្មរួចស្ទើរតែទាំងអស់ មានទំនាក់ទំនងជាមួយនឹងការចុះឈ្មោះចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីការងារវិជ្ជាជីវៈជាមួយនឹងអង្គការ (ដែលកម្មវិធីទាំងនេះផ្តល់សេវាកម្មដូចជា ការថែរទាំសុខភាព ការប្រឹក្សាយោបល់ និងជំនួយខាងផ្នែកការងារសង្គមកិច្ចជាដើម)។ យើងនៅតែមើលឃើញថា ប្រសិនបើអតិថិជនបានចំណាយពេលរស់នៅក្នុងកម្មវិធីមណ្ឌល ពួកគេមានសមត្ថភាពក្នុងការបង្កើតអាពាហ៍ពិពាហ៍ ដែលចេះលើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមកបានច្រើនជាងអតិថិជនដទៃទៀតពីពេលមួយទៅពេលមួយ។ ជនរួចពីរងគ្រោះស្ទើរតែទាំងអស់នៅក្នុងក្រុមទាំងនេះ គឺជាក្រុមដែលមានវ័យក្មេង ហើយជាអ្នកនៅលីវ ឬទើបតែបានរៀបការថ្មីៗ (ក្រុមស្រ្តី/ក្មេងស្រី និងក្រុមបុរស/ក្មេងប្រុសរស់នៅក្នុងមណ្ឌល ហើយបានធ្វើសមាហរណកម្មរួច)។ ដោយសារគម្រោងស្រាវជ្រាវមេអំបៅរយៈពេលវែងនៅតែបន្ត ទិន្នន័យជាច្រើននឹងត្រូវបានវាយតម្លៃផ្សេងៗគ្នា ក្នុងក្រុមវាយតម្លៃនេះ។

នៅក្នុងការសិក្សា ក៏បានបញ្ជាក់ពីចំនុចឡើងចុះផ្សេងៗទៀតនៅក្នុងជីវិតរបស់ជនរួចពីរងគ្រោះទាំងចំនុចវិជ្ជមាន និងចំនុចអវិជ្ជមាន។ ជនរួចពីរងគ្រោះបាននិយាយពីក្តីសង្ឃឹមទៅអនាគតរួមទាំង ការមានការងារ ដែលអាចរកប្រាប់ចំណូលបានសមរម្យសម្រាប់ផ្គត់ផ្គង់គ្រួសារ។ ការងារទាំងនេះភាគច្រើន ជាប្រភេទការងារធ្វើជាមួយអង្គការ ប៉ុន្តែក៏មានជនរួចពីរងគ្រោះពីរនាក់ដែរ ដែលបាននិយាយពីការងារនៅក្នុងវិស័យអាជីវកម្មឯកជន។ ជនរួចពីរងគ្រោះ០៦នាក់បាននិយាយពីការចុះឈ្មោះចូលរៀនម្តងទៀតជាមួយវគ្គបណ្តុះបណ្តាលការងារវិជ្ជាជីវៈជាមួយកម្មវិធីអង្គការ ដែលកន្លងមក ការងារប្រភេទនេះអាចជួយឲ្យគេមានការងារមួយ ដែលមានប្រាក់ចំណូលសមរម្យនៅក្នុងសហគមន៍។ អតិថិជនខ្លះទៀតក៏បាននិយាយអំពីតួនាទីជាវិជ្ជមានរបស់ឪពុកម្តាយ ដែលបានដើរតួយ៉ាងសំខាន់នៅក្នុងការបង្កើតឱកាសទទួលបានការអប់រំ និងស្ថេរភាពហិរញ្ញវត្ថុ។ ជនរួចពីរងគ្រោះក៏បាននិយាយផងដែរ អំពីការលំបាកនៅពេលពួកគេមានផ្ទៃពោះ ជាពិសេសប្រសិនបើអតិថិជននេះមានផ្ទៃពោះទាំងមិនទាន់រៀបការ ហើយពួកគេដឹងថាគ្រួសារពួកគេមិនយល់ព្រមចំពោះរឿងនេះ។ ជាញឹកញាប់ អតិថិជនដែលមានផ្ទៃពោះបានរៀបរាប់ពីបញ្ហាដូចជា ការឈប់ពីការងារដែលមានប្រាក់ចំណូលទៀងទាត់ ការផ្លាស់ប្តូរទីលំនៅទៅរស់នៅជាមួយគ្រួសារ ការជំពាក់បំណុលច្រើន និង/ឬការព្រួយបារម្ភផ្សេងៗទៀត ដែលទាក់ទងនឹងបញ្ហាសុខភាពកូនទើបនឹងកើតជាដើម។ ចំនុចឡើងចុះទាំងវិជ្ជមាន និងអវិជ្ជមានទាំងអស់នេះ ភាគច្រើនគឺជាលទ្ធផលនៃការសម្រេចចិត្តរបស់ជនរួចពីរងគ្រោះផ្ទាល់តែម្តង។

### 3.2.2 ការធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងសហគមន៍

ទំនាក់ទំនងជាមួយឪពុកម្ដាយ ទាំងទំនាក់ទំនងល្អ ឬមិនល្អ គឺពិតជាជះឥទ្ធិពលទៅលើការធ្វើសេចក្ដីសម្រេចចិត្ត និងការបង្កើតទំនាក់ទំនងដល់ក្រុមអតិថិជនភាគច្រើននៅក្នុងសិក្សានេះ នៅពេលដែលពួកគេឈានចូលដល់យុវវ័យ។ ការសិក្សាមួយចំនួនបានបង្ហាញពីតួនាទីរបស់ឪពុកម្ដាយ ជាពិសេសចំពោះឥរិយាបថក្នុងការឆ្លើយតប និងគាំទ្រចំពោះកូន ដែលវាដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍សមត្ថភាពកុមារដើម្បីឲ្យកុមារអាចបង្កើតការភ្ជាប់ទំនាក់ទំនងដោយសុវត្ថិភាពបាន ហើយវាក៏ជាចំនុចការពារមួយដ៏ចម្បងសម្រាប់សមត្ថភាពក្នុងការស្តារខ្លួនឯងនៅក្នុងជីវិតពួកគេ (Noltemeyer and Bush 2013)។ ជាទូទៅ កុមារក៏ដូចជាមនុស្សធំដែរ កុមារដែលចេះរៀនបង្កើតការភ្ជាប់ទំនាក់ទំនងដោយសុវត្ថិភាព ពួកគេមានសមត្ថភាពក្នុងការបង្កើតនូវទំនាក់ទំនង ដែលអាចទុកចិត្តបាន និងទំនាក់ទំនងយូរអង្វែង ចេះឲ្យតម្លៃខ្លួនឯងខ្ពស់ មានសមត្ថភាពអាចបង្ហាញ និងចែកចាយពីអារម្មណ៍ជាមួយដៃគូរ (ប្តី/ប្រពន្ធ) និងមានសមត្ថភាពក្នុងស្វែងរក ឬបង្កើតមិត្តភាពដែលចេះគាំទ្រគ្នាទៅវិញទៅមក នៅពេលពួកគេត្រូវការ។

នៅពេលជនរួចពីរងគ្រោះបានធ្វើសមាហរណកម្មត្រលប់ទៅរស់នៅក្នុងសហគមន៍វិញ នោះការធ្វើការសម្រេចចិត្ត និងរចនាសម្ព័ន្ធក្នុងការសម្រេចចិត្ត ត្រូវបានផ្លាស់ប្តូរពីទំនួលខុសត្រូវរបស់មណ្ឌល ទៅឱ្យឪពុកម្តាយ ឬគ្រួសាររបស់ពួកគេ និង/ឬអតិថិជនខ្លួនឯងផ្ទាល់តែម្តង។ អតិថិជនក្មេងៗមួយចំនួនដែលបានធ្វើសមាហរណកម្មរួចហើយ (ទាំងអតិថិជនជាក្មេងប្រុស និងអតិថិជនជាក្មេងស្រី) បាននិយាយអំពីតួអង្គឪពុកម្តាយ ដែលចូលរួមក្នុងដំណើរការនៃការសម្រេចចិត្តនេះ ដោយផ្តល់ឲ្យពួកគេមាននូវសេរីភាពច្រើន ឬតិចជាង។ ជាទូទៅ នៅក្នុងចំណោមក្រុមអតិថិជនទាំងអស់ អតិថិជនជាបុរស/ក្មេងប្រុសភាគច្រើនមានការលំបាកក្នុងការធ្វើសេចក្តីសម្រេចចិត្តឱ្យបានល្អទាក់ទងនឹងគ្រឿងញៀន និងគ្រឿងស្រវឹង។ ចំណែកអតិថិជនជាស្ត្រី/ក្មេងស្រីវិញ ភាគច្រើនជួបបញ្ហាលំបាកក្នុងការសម្រេចចិត្តទាក់ទងនឹងជម្រើសក្នុងការទំនាក់ទំនង និងបញ្ហាអំពើហិង្សានៅក្នុងគ្រួសារ។ អតិថិជនក្នុងក្រុមស្ត្រី ដែលធ្វើសមាហរណកម្មរួច និយាយអំពីការធ្វើការសម្រេចចិត្ត ដែលប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ដូចជា ការទំនាក់ទំនងជាមួយបុរស (ឧទាហរណ៍ដូចជា រៀបការជាមួយបុរស ដែលមិនបានស្គាល់ពីមុន តែដោយសារការច្រឡំលេខទូរស័ព្ទខណៈពេលស្រវឹងស្រា។) ការដោះស្រាយបញ្ហាលំបាកៗ (ឧទាហរណ៍៖ ញ៉ាំស្រាពេលមានបញ្ហាអំពើហិង្សានៅក្នុងគ្រួសារ។) រកប្រាក់ដើម្បីផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារ (ឧទាហរណ៍៖ ត្រលប់ទៅធ្វើការរកស៊ីផ្លូវភេទវិញ ឬចំណាកស្រុកដើម្បីស្វែងរកការងារធ្វើនៅប្រទេសថៃជាដើម)។

ការសិក្សាស្រាវជ្រាវរយៈពេលវែងនេះ ផ្តល់នូវឱកាសដើម្បីឲ្យយើងយល់កាន់តែច្បាស់ថែមទៀត អំពីកត្តារុញច្រានក្នុងជីវិតជនរួចពីរងគ្រោះនៅកន្លែងធ្វើការ។ ជាញឹកញាប់ អតិថិជនក្នុងការសិក្សាបានបង្ហាញថា កត្តារុញច្រានទាំង13ចំនុចនេះ មានទំនាក់ទំនងនឹងការធ្វើសេចក្តីសម្រេចចិត្ត ដែលធ្វើឲ្យការងារ និង/ឬភាពឆាប់ត្រលប់មកធម្មតាវិញរបស់ពួកគេមានការផ្លាស់ប្តូរ។ ជាញឹកញាប់ អតិថិជនភាគច្រើនបាននិយាយរៀបរាប់ពីបំណុល ប្រាក់ចំនូលមិនសមរម្យ និងកាតព្វកិច្ចក្នុងការរកប្រាក់ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។ ការសិក្សាស្រាវជ្រាវនេះបានបញ្ជាក់ថា ការសម្រេចចិត្តរបស់ជនរួចពីរងគ្រោះមានការស្មុគស្មាញ ហើយការសម្រេចចិត្តនោះ មិនត្រឹមគ្រាន់តែពាក់ព័ន្ធនឹងបញ្ហាការរកប្រាក់ចំណូលប៉ុណ្ណោះទេ។ នៅក្នុងការសិក្សាស្រាវជ្រាវរយៈពេលប្រមាណជាបួនឆ្នាំកន្លងមកនេះ អតិថិជន ដែលបានធ្វើសមាហរណកម្មរួច បានបង្ហាញថា មួយក្នុងចំណោមកត្តារុញច្រានទាំងដប់បី ការធ្វើការសម្រេចចិត្ត គឺជាកត្តាមួយដ៏សំខាន់ ដែលតែងតែកើតឡើងម្តង ឬច្រើនជាងនេះ ក្នុងចំណោមកត្តារុញច្រានទាំងអស់ដែលបណ្តាលឲ្យការងារ និង/ឬភាពឆាប់ត្រលប់មកធម្មតាវិញរបស់ពួកគេមានការផ្លាស់ប្តូរ។ ជាញឹកញាប់ កត្តារុញច្រានទាំងនេះហាក់បីដូចជាច្របល់បញ្ចូលគ្នា នៅពេលជនរួចពីរងគ្រោះរៀបរាប់អំពីការសម្រេចចិត្តរបស់ពួកគេ និងបុព្វហេតុដែលធ្វើឲ្យជីវិតពួកគេប្រែប្រួល។ ជនរួចពីរងគ្រោះម្នាក់បានរៀបរាប់ពីកត្តាទាំងនេះដែលកើតឡើងក្នុងជីវិតការងាររបស់នាងចាប់ពីឆ្នាំ 2013 ដល់ឆ្នាំ2014។ ខាងក្រោមជាពាក្យសម្តីរបស់នាង៖

| <u>**ស្ត្រីរួចពីរងគ្រោះ នៅអាយុ 28ឆ្នាំ និង29ឆ្នាំ**</u> | <u>**កត្តារុញច្រានក្នុងឆ្នាំ *2013***</u> |
| --- | --- |
| *(2013)* - ខ្ញុំបានធ្លាប់ប្តូរការងារមកធ្វើការជាអ្នកបម្រើតាមផ្ទះ។ ឥឡូវខ្ញុំបានប្រាក់ខែ140ដុល្លារក្នុងមួយខែ។ ប៉ុន្តែធ្វើការនៅទីនេះមិនដូចកន្លែងធ្វើការចាស់របស់ខ្ញុំទេ។ នៅកន្លែងធ្វើការចាស់ ខ្ញុំមានទំនាក់ទំនងល្អជាមួយមិត្តភក្តិធ្វើការជាមួយគ្នា តែធ្វើការនៅទីនេះ អ្នកធ្វើការជាមួយខ្ញុំ គេឆ្មើងណាស់ ហើយតែងតែធ្វើឲ្យខ្ញុំមិនសប្បាយចិត្ត។ | ស្វែងរកឱកាសការងារប្រសើរជាងមុន<br>ជម្លោះនៅកន្លែងការងារ<br>អារម្មណ៍មិនសប្បាយចិត្ត |
| ពួកគេចាប់ផ្តើមឈប់និយាយជាមួយខ្ញុំ នៅពេលគេដឹងពីរឿងអតីតកាលរបស់ខ្ញុំ។ ពួកគេយល់ច្រឡំពីខ្ញុំ ហើយលែងចាត់ទុកថាខ្ញុំជាមនុស្សល្អទៀតហើយ។ ពួកគេនិយាយរឿងខ្ញុំទៅប្រាប់អ្នកទើប ចូលធ្វើការថ្មី។ | ស្លាកស្នាមទុរយសក្នុងសហគមន៍ |
| ឥឡូវម្តាយរបស់ខ្ញុំគាត់ចាស់ ហើយគ្មាននរណានៅមើលថែគាត់ទេ។ ខ្ញុំត្រូវផ្ញើរលុយទៅផ្ទះរៀងរាល់ខែ ហើយពេលខ្លះខ្ញុំត្រូវជួយក្មួយខ្ញុំដែលធ្វើការនៅថៃទៀត។ ខ្ញុំមិនសូវសប្បាយចិត្តទេ។ | កាតព្វកិច្ចគ្រួសារ<br>អារម្មណ៍មិនសប្បាយចិត្ត |
| គ្រួសារខ្ញុំជំពាក់លុយគេ ហើយខ្ញុំត្រូវផ្ញើរលុយទៅផ្ទះជួយសងថ្លៃជំពាក់គេ រួមទាំងការប្រាក់ឲ្យពួកគាត់ ព្រោះឪពុកម្តាយខ្ញុំគាត់ចាស់ហើយមិនអាចធ្វើការអ្វីកើតទៀត។ | បំណុល<br>កាតព្វកិច្ចគ្រួសារ |
| ឪពុកម្តាយរបស់ខ្ញុំមានជម្ងឺ។ សុខភាពខ្ញុំមិនសូវល្អទេ ហើយខ្ញុំក៏ឧស្សាហ៍ឈឺ ណាស់ដែរ។ | សុខភាពផ្ទាល់ខ្លួន<br>សុខភាពគ្រួសារ |
| *(2014)* - ខ្ញុំមានការលំបាកណាស់ក្នុងការធ្វើការជាមួយថៅកែរបស់ខ្ញុំ។ | <u>**កត្តារុញច្រានក្នុងឆ្នាំ 2014**</u><br>ជម្លោះកន្លែងការងារ |
| ឥឡូវខ្ញុំឈប់ធ្វើការហើយ ព្រោះខ្ញុំប៉ះពាល់ពាក្យសម្តីជាមួយថៅកែខ្ញុំ ហើយម្យ៉ាងទៀតសុខភាពខ្ញុំអត់ល្អ។ ខ្ញុំមកនៅផ្ទះជាមួយឪពុកម្តាយខ្ញុំនៅខេត្តដោយសារខ្ញុំឈឺ។ ខ្ញុំបានចាយលុយរបស់ខ្ញុំ អស់ទៅលើការទិញថ្នាំសម្រាប់ព្យាបាលជម្ងឺ។ ឥឡូវខ្ញុំចង់ស្វែងរកការងារធ្វើផ្សេងទៀត។ | សុខភាពផ្ទាល់ខ្លួន<br>គ្មានការងារធ្វើ<br>ប្រាក់ចំណូលមិនគ្រប់គ្រាន់ |

### 3.2.3 ការបញ្ចេញមតិអំពីភាពឆាប់ត្រលប់មកធម្មតាវិញ

ជាញឹកញាប់ ការបញ្ចេញមតិអំពីភាពឆាប់ត្រលប់មកធម្មតាវិញរបស់ជនរួចពីរងគ្រោះបានបង្ហាញតាមរបៀបជាច្រើន ទាក់ទងនឹងសមត្ថភាពរបស់ពួកគេ ក្នុងការសម្របខ្លួនទៅនឹងកាលៈទេសៈលំបាកៗនៅក្នុងជីវិត។ ជនរួចពីរងគ្រោះបានបង្ហាញអារម្មណ៍ទាក់ទងនឹងសុខុមាលភាព ហើយពេលខ្លះបង្ហាញអំពីការស៊ូទ្រាំពេលជួបឧបសគ្គ និងបញ្ហាប្រឈមនានា។ មានប្រធានបទរួមចម្បងចំនួនដប់ពាក់ព័ន្ធនឹងភាពឆាប់ត្រលប់មកធម្មតាវិញ ត្រូវបានរកឃើញ យោងតាមការឆ្លើយតប និងការបង្ហាញរបស់អតិថិជននៅក្នុងគម្រោង។ ជាទូទៅ ប្រធានបទរួមនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងប្រធានបទរួមនៅក្នុងរបាយការណ៍សិក្សារបស់ Gray (2012)។ ការបង្ហាញពីការសម្របខ្លួនរបស់ជនរួចពីរងគ្រោះត្រូវបានរកឃើញថាមានចំនួនតិចតួចបំផុតក្នុងចំណោមអតិថិជនក្នុងការសិក្សារបស់យើងនេះ។

ប្រធានបទរួមស្ដីអំពីភាពឆាប់ត្រលប់មកធម្មតាវិញ ដែលកើតឡើងជាញឹកញាប់ក្នុងចំណោមអតិថិជនក្នុងការសិក្សានេះ គឺសមត្ថភាពក្នុងការខិតខំតស៊ូធ្វើការងារ និងការឆ្លុះបញ្ចាំងពីការតស៊ូព្យាយាមក្នុងការធ្វើការដើម្បីសម្រេចនូវគោលដៅ ឬដើម្បីបំពេញកាតព្វកិច្ចនិងទំនួលខុសត្រូវក្នុងគ្រួសារ។ ការសិក្សាដទៃផ្សេងទៀតស្ដីពីភាពឆាប់ត្រលប់មកធម្មតាវិញនៅប្រទេសកម្ពុជាបានបញ្ជាក់ថា ការខិតខំតស៊ូធ្វើការ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងភាពឆាប់វិលត្រលប់មកធម្មតាវិញរបស់ជនរួចពីរងគ្រោះនៅក្នុងសម័យរបបខ្មែរក្រហម (Overland, 2012)។ ពេលខ្លះ ការស្ម័គ្រចិត្តខំប្រឹងធ្វើការបង្ហាញពីកម្លាំងជំរុញចិត្តដើម្បីសម្រេចជោគជ័យលើការងារអ្វីមួយ វាបង្ហាញពីបុគ្គលិកលក្ខណៈមួយដ៏សំខាន់របស់ជនរួចពីរងគ្រោះ ដែលធ្វើសមាហរណកម្មទៅសហគមន៍វិញ (Muco, 2013)។ ខណៈពេល ដែលនៅក្នុងកម្មវិធីមណ្ឌលមានអតិថិជនមួយចំនួនបញ្ជាក់ថា ឪពុកម្ដាយ ឬបុគ្គលិកមណ្ឌលបានលើកទឹកចិត្តពួកគេឲ្យខិតខំប្រឹងប្រែងធ្វើការ និងខិតខំរៀនសូត្រ ក៏មានអតិថិជនជាច្រើននាក់បានបញ្ជាក់ពីសមត្ថភាពរបស់ពួកគេក្នុងការធ្វើការងារធ្ងន់ៗនៅក្នុងកាលៈទេសៈលំបាកផ្សេងៗដូចជា ក្លាយជាជនបង្គោលក្នុងការមើលថែគ្រួសារបន្ទាប់ពីម្ដាយរបស់ខ្លួនបានស្លាប់ទៅ, ការធ្វើការ និងការតស៊ូយ៉ាងលំបាកផ្សេងៗ ដូចជាក្លាយជាកម្មករចំណាកស្រុកទៅប្រទេសក្រៅ (ឧទាហរណ៍នៅប្រទេសថៃ), ការធ្វើការដើម្បីបំពេញកាតព្វកិច្ចទំនួលខុសត្រូវក្នុងគ្រួសារ, ការខិតខំរៀនសូត្រ និងការខិតខំប្រឹងធ្វើការដើម្បីបង្កើតអាជីវកម្មផ្ទាល់ខ្លួន។ ទោះបីជាពេលខ្លះជួបប្រទះនូវស្ថានភាពអវិជ្ជមាននៅក្នុងជីវិតក៏ដោយ ជាញឹកញាប់អតិថិជន ភាគច្រើនបានបង្ហាញចេញពីអារម្មណ៍ពេញចិត្តចំពោះជីវិតរបស់ពួកគេដោយផ្អែកលើការខិតខំប្រឹងប្រែងធ្វើការ និងការចូលរួមចំណែកក្នុងការផ្គត់ផ្គង់គ្រួសារ។

អតិថិជនភាគច្រើនមានបញ្ហាលំបាកក្នុងការសម្របខ្លួន និងរក្សាតុល្យភាពលំនឹងការងារ និងការបំពេញកាតព្វកិច្ចចម្បងផ្សេងៗក្នុងជីវិតរបស់ពួកគេ។ អតិថិជនមួយចំនួនដែលមានផ្ទៃពោះបានរៀបរាប់ពីការឈប់ពីការងារ ដែលអាចរកប្រាក់ចំណូលបានទៀងទាត់ ដែលបង្ហាញឲ្យឃើញថា ពួកគេនៅមិនទាន់អាចស្វែងរកមធ្យោបាយក្នុងការថែរទាំកូនៗរបស់ពួកគ និងនៅតែមិនអាចបន្តធ្វើការងារបាននៅឡើយ។ ដើម្បីដោះស្រាយភាពតានតឹងផ្នែកហិរញ្ញវត្ថុ កាតព្វកិច្ចគ្រួសារ និងបញ្ហាបំណុល អតិថិជនក្នុងវ័យជាសិស្សមួយចំនួនបានឈប់ទៅសាលា ដើម្បីស្វែងរកការងារធ្វើក្នុងការជួយផ្គត់ផ្គង់គ្រួសារ។ អតិថិជនវ័យក្មេងស្ទើរតែទាំងអស់មិនទាន់មានសមត្ថភាព ក្នុងការរក្សាលំនឹងរវាងការសិក្សា និងការស្វែងរកការងារធ្វើដើម្បីចូលរួមចំណែកក្នុងការផ្គត់ផ្គង់គ្រួសាររបស់ពួកគេបានតាមរបៀបសមរម្យនៅឡើយទេ។ មានតែអតិថិជនវ័យក្មេងពីរនាក់ប៉ុណ្ណោះ ដែលបាននិយាយពីការបន្តការសិក្សា ហើយពួកគេនៅតែអាចជួយរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារដោយសារលក់ក្រដាសឆ្នោត។ មិនមានអតិថិជនណាមួយ ដែលអាចស្វែងរកមធ្យោបាយដើម្បីអាចធ្វើការបានផង និងអាចរៀនកម្មវិធីវគ្គបណ្តុះបណ្តាលផងបានទេ ប្រសិនបើកម្មវិធីទាំងនោះ ផ្តល់ជំនួយថវិការមានកំនត់ ឬមិនបានផ្តល់ជំនួយសោះ។

គ្មានអតិថិជនណាម្នាក់និយាយអំពីការចូលរួមជាមួយក្រុមជំនុំ ឬសកម្មភាពសាសនានៅក្នុងសហគមន៍ទេក្រៅពីមានការជួយសម្របសម្រួលពីអង្គការ។ ចំណុចនេះនៅក្នុងសហគមន៍ពិតជាមានសារៈសំខាន់ណាស់ក្នុងការភ្ជាប់ទំនាក់ទំនងរបស់ជនរួចពីរងគ្រោះ ហើយវាជាកត្តាស្នូលចម្បងសម្រាប់ការកសាងភាពឆាប់ត្រលប់មកធម្មតាវិញរបស់កុមារ ឬមនុស្សវ័យជំទង់ និងមនុស្សវ័យកណ្តាល (Werner 1993; Hawkins et al. 2009; Nowak-Carter 2012; Murco 2013)។ ជនរួចពីរងគ្រោះមួយចំនួនបាននិយាយពីការភ្ជាប់ទំនាក់ទំនងជាមួយក្រុមជំនុំក្នុងសហគមន៍ បន្ទាប់ពីធ្វើសមាហរណកម្មរួច ប៉ុន្តែស្ទើរតែទាំងអស់បានបញ្ជាក់ថា ការភ្ជាប់ទំនាក់ទំនងនេះ គឺវាប្រៀបដូចជាផ្ទះរបស់គេដែរ ដែលវាមានការសម្របសម្រួលពីអង្គការឲ្យពួកគេបានស្នាក់នៅទីនោះ ដោយសារពួកគេស្ថិតនៅក្រោមការតាមដាននៃកម្មវិធីធ្វើសមាហរណកម្មរបស់អង្គការ។ គួរឲ្យសោកស្តាយ និន្នាការនេះទំនងជាមិនផ្លាស់ប្តូរទេ ទោះបីជាចំនួនជនរួចពីរងគ្រោះដែលបញ្ចប់ដំណើរការសមាហរណកម្មមានចំនួនកើនឡើងក៏ដោយ និងជនរួចពីភាពរងគ្រោះបាត់នូវទំនាក់ទំនងជំនួយសំខាន់ៗក្រៅពីសហគមន៍របស់ពួកគេ (ឧទាហរណ៍៖ បុគ្គលិកតាមដានសមាហរណកម្មរបស់អង្គការ)។

## 4.0 លទ្ធផលនៃការសិក្សា និងអនុសាសន៍

គម្រោងសិក្សាស្រាវជ្រាវមេអំបៅរយៈពេលវែងនេះ គឺជាលទ្ធផលនៃការឆ្លើយតបរួមមួយរបស់បណ្តាភ្នាក់ងារប្រយុទ្ធប្រឆាំងនឹងការជួញដូរក្នុងសម្ព័ន្ធរបស់អង្គការចាប់ដៃ ដែលបានកំពុងធ្វើការជាមួយជនរងគ្រោះ ឬជនរួចពីរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទអស់រយៈពេលជាងពីរទសវត្ស (Delaney and Scarff 2010; Derks et al. 2006)។ រយៈពេលជាច្រើនឆ្នាំមកនេះ កម្មវិធីជំនួយ និងបណ្តាភ្នាក់ងារទាំងនេះបានបង្ហាញពីបំណងចិត្តក្នុងការសិក្សាពីចំណុចខ្លាំង និងចំណុចខ្សោយរបស់កម្មវិធីរបស់ខ្លួន ជាពិសេសចំពោះបទពិសោធន៍រយៈពេលវែងនៃការធ្វើសមាហរណកម្មរបស់អតិថិជន។ គោលបំណងនៃរបាយការណ៍សិក្សាស្តីពីប្រធានបទរួមនេះ គឺដើម្បីបង្កើនការយល់ដឹងឲ្យបានកាន់តែទូលំទូលាយថែមទៀតស្តីពីភាពឆាប់ត្រលប់មកធម្មតាវិញរបស់ជនរួចពីរងគ្រោះដោយសារការកេងប្រវ័ញ្ច និងជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់ "សម្លេងរួម" របស់ពួកគេ។ តាមរយៈការសិក្សានេះ ជនរួចពីរងគ្រោះបានបញ្ចេញពីអារម្មណ៍របស់ពួកគេ ដែលពាក់ព័ន្ធនឹងភាពឆាប់ត្រលប់មកធម្មតាវិញ តាមរបៀបផ្សេងៗជាច្រើន និងបង្ហាញពីក្តីសង្ឃឹមរបស់ពួកគេសម្រាប់ពេលអនាគត ព្រមជាមួយនឹងការបង្ហាញពីសមត្ថភាពក្នុងការស៊ូទ្រាំ និងសមត្ថភាពសម្របខ្លួន នៅពេលពួកគេជួបនូវឧបសគ្គលំបាក និងបញ្ហាប្រឈមនានាដែលកើតមានជាញឹកញាប់នៅក្នុងជីវិត។ តាមរយៈការផ្សព្វផ្សាយពី "សម្លេងរួម" របស់ពួកគេ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ អង្គការសម្ព័ន្ធចាប់ដៃសង្ឃឹមថាកម្មវិធីសមាហរណកម្ម និងការរៀបចំគោលនយោបាយផែនការណ៍នានានឹងទទួលបានព័ត៌មាននេះ ដើម្បីធ្វើឲ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត សម្រាប់ជាប្រយោជន៍យ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាពជីវិតរស់នៅរបស់ជនរួចពីរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងបណ្តាប្រទេសនានានៅទូទាំងពិភពលោក។

ខាងក្រោម គឺជាអនុសាសន៍នានាដែលបានធ្វើឡើងដោយផ្អែកទៅលើលទ្ធផលដែលបានរកឃើញនៅក្នុងសិក្សានេះ៖

1. **លទ្ធផលនៃការសិក្សា៖** កម្រិតដែលជនរួចពីរងគ្រោះអាចបង្កើតទំនាក់ទំនងដែលចេះលើកទឹកចិត្ត និងចេះគាំទ្រគ្នាទៅវិញទៅមក ជាមួយគូរស្រករ អាចកំណត់ថាតើការសម្រេចចិត្តនេះនឹងក្លាយជាចំនុចឡើងចុះជាវិជ្ជមាន ឬអវិជ្ជមាននៅក្នុងដំណើរជីវិតរបស់ពួកគេនាពេលខាងមុខ។
   **អនុសាសន៍៖** ផ្តល់ការបណ្តុះបណ្តាលអំពីអាពាហ៍ពិពាហ៍ និងទំនាក់ទំនងសម្រាប់ជនរួចពីរងគ្រោះ ដែលស្នាក់នៅក្នុងមណ្ឌល ផ្ទះបណ្តោះអាសន្ន និងធ្វើការក្នុងកម្មវិធីជំនួយ គឺជាអនុសាសន៍ដ៏សំខាន់តែមួយគត់ ដែលការសិក្សាស្រាវជ្រាវផ្តល់អោយ។ ការសម្រេចចិត្តអំពី

អាពាហ៍ពិពាហ៍ គឺពិតជាលំបាក និងមានភាពស្មុគស្មាញសម្រាប់ជនរួចពីរងគ្រោះ ហើយអតិថិជនភាគច្រើនក្នុងការស្រាវជ្រាវនេះកំពុងតែជួបប្រទះបញ្ហាសម្រេចចិត្ត ដែលទាក់ទងនឹងបញ្ហាទំនាក់ទំនងនេះ។ វគ្គបណ្តុះបណ្តាលស្តីពីការកសាងទំនាក់ទំនង និងការធ្វើការសម្រេចចិត្ត គឺជាអនុសាសន៍ដែលសំខាន់បំផុត។

2. **លទ្ធផលនៃការសិក្សា៖** ទំនាក់ទំនងល្អជាមួយឪពុកម្តាយមានឥទ្ធិពលយ៉ាងសំខាន់ទៅលើភាពឆាប់ត្រលប់មកធម្មតាវិញរបស់យុវវ័យ។ ទំនាក់ទំនងល្អរវាងឪពុកម្តាយជាមួយជនរួចពីរងគ្រោះជាយុវវ័យ ក៏នឹងមានឥទ្ធិពលសំខាន់ដល់ជីវិតរបស់ពួកគេ និងរៀបចំពួកគេឱ្យក្លាយជាមនុស្សពេញវ័យដែរ។

   **អនុសាសន៍៖** កម្មវិធីជំនួយស្នាក់នៅមណ្ឌល និងសូម្បីតែផ្ទះស្នាក់នៅបណ្តោះអាសន្នគួរតែគិតអំពីការបង្កើតផែនការណ៍ក្នុងការសម្របសម្រួល ធ្វើឲ្យទំនាក់ទំនងគ្រួសារកាន់តែជិតស្និទ្ធហើយស្របពេលជាមួយគ្នាដែរ ក៏ជួយកសាងសមត្ថភាពរបស់ជនរួចពីរងគ្រោះក្នុងការស្តារខ្លួនឯងឡើងវិញ មុនពេលដែលពួកគេធ្វើសមាហរណកម្ម។ ការបណ្តុះទំនាក់ទំនងគ្រួសារល្អរវាងអតិថិជនជាមួយនឹងមនុស្សធំនៅក្នុងគ្រួសារយ៉ាងហោចណាស់ម្នាក់ នៅពេលពួកគេកំពុងរស់នៅក្នុងកម្មវិធីមណ្ឌល (ប្រសិនបើកាលៈទេសៈអំណោយផលអោយ) អាចមានសារប្រយោជន៍ជាវិជ្ជមានយ៉ាងសំខាន់ចំពោះជីវិតកុមារនៅក្នុងការស្តារសមត្ថភាពរបស់ពួកគេឡើងវិញ នាពេលខាងមុខ។

3. **លទ្ធផលនៃការសិក្សា៖** ពេលជនរួចពីរងគ្រោះធ្វើសមាហរណកម្ម ការធ្វើការសម្រេចចិត្ត និងនាមជាអ្នកថែរក្សា ត្រូវបានផ្លាស់ប្តូរពីទំនួលខុសត្រូវរបស់មណ្ឌល ត្រលប់ទៅជាទំនួលខុសត្រូវរបស់គ្រួសារ និង/ឬរបស់អតិថិជនផ្ទាល់តែម្តង។

   **អនុសាសន៍៖** អង្គការក្រៅរដ្ឋាភិបាលគួរតែធ្វើការពិចារណាពីកិច្ចសហការជាមួយគម្រោងណាមួយ ដើម្បីបង្កើតកម្មវិធីសិក្សាស្តីពីការគិតឆ្ពោះទៅមុខ ដែលផ្តោតលើមនុស្សវ័យជំទង់ រហូតពេញវ័យ (អាយុចាប់ពី16ឆ្នាំ ទៅដល់20ឆ្នាំ)។ ធនធាននានា គឺពិតជាត្រូវការដើម្បីបង្កើនការយល់ដឹងរបស់ជនរួចពីរងគ្រោះ និងបង្កើនការយល់ដឹងអំពីឥទ្ធិពលនៃកត្តារុញច្រានផ្សេងៗក្នុងជីវិតរបស់ពួកគេ បន្ទាប់ពីធ្វើសមាហរណកម្មរួច (ឧទាហរណ៍៖ ប្រធានបទដូចជាការមានផ្ទៃពោះ ឬវិធីសាស្រ្តក្នុងការធ្វើការសម្រេចចិត្តទាក់ទងនឹងការធ្វើការងារធ្វើនៅពេលមានឱកាសការងារប្រសើរជាមុននៅកន្លែងផ្សេងជាដើម)។

4. **លទ្ធផលនៃការសិក្សា៖** មានឧទាហរណ៍ជាច្រើន ដែលបង្ហាញពីកម្មវិធីអង្គការដែលជួយភ្ជាប់ទំនាក់ទំនងជនរួចពីរងគ្រោះជាមួយសហគមន៍ក្រុមជំនុំ និងអង្គការផ្សេងទៀតនៅក្នុងតំបន់របស់ពួកគេ។ យោងតាមការសិក្សានេះ ជនរួចពីរងគ្រោះភាគច្រើនមិនសូវមានចំណេះដឹង ឬជំនាញគ្រប់គ្រាន់ក្នុងការបង្កើតបណ្តាញខ្លួនឯងផ្ទាល់នោះទេ។ មិនមានអតិថិជនណាមួយនិយាយអំពីការចូលរួមក្រុមជំនុំ ឬសកម្មភាពសាសនាក្នុងសហគមន៍ទេបន្ទាប់ពីចាកចេញពីមណ្ឌល។ គួរឲ្យសោកស្តាយ និន្នាការនៅក្នុងការសិក្សារបស់យើង ទំនងជាមិនផ្លាស់ប្តូរទេ ទោះបីជាចំនួនជនរួចពីរងគ្រោះដែលបញ្ចប់ដំណើរការសមាហរណកម្ម (ចាកចេញពីកម្មវិធីអង្គការ) មានចំនួនកើនឡើងក៏ដោយ។

   **អនុសាសន៍៖** អប់រំ និងបណ្តុះអ្នកដឹកនាំក្រុមជំនុំ និងបណ្តាញនៅក្នុងក្រុមជំនុំ ឬសកម្មភាពសាសនានៅក្នុងសហគមន៍ ដើម្បីផ្តល់នូវតួនាទីដ៏សំខាន់ក្នុងការគាំទ្រ និងការចុះទៅដល់ជនរួចពីរងគ្រោះ និងផ្តល់ឲ្យនូវឱកាសក្នុងការភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍ដែលមានទំនាក់ទំនងល្អ និងចេះជួយគាំទ្រគ្នាទៅវិញទៅមក។ ការបណ្តុះសមត្ថភាពជនរួចពីរងគ្រោះឲ្យចេះកំណត់រចនាសម្ព័ន្ធគាំទ្រក្នុងសហគមន៍ដូចជា ស្ថាប័នសាសនា និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ នឹងជួយឲ្យពួកគេកាន់តែមានឯករាជ្យភាព និងមានសមត្ថភាពថែមទៀតក្នុងសហគមន៍របស់ពួកគេ។

5. **លទ្ធផលនៃការសិក្សា៖** ការសិក្សានេះបានបង្ហាញថា គ្រួសារអតិថិជនស្ទើរតែទាំងអស់ មានការលំបាកទាក់ទងនឹងការរកប្រាក់ក្នុងការផ្គត់ផ្គង់ការរស់នៅ។ អតិថិជនភាគច្រើនដែលធ្វើការជាមួយកម្មវិធីជំនួយរបស់អង្គការ បង្ហាញថាពួកគេអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ក្នុងការបំពេញតម្រូវការគ្រួសារគេបាន។ ការងារផ្នែកសម្អាតនៅក្នុងវិស័យបដិសណ្ឋារកិច្ច និងការងារជាអ្នកគ្រប់គ្រងនៅក្នុងវិស័យរោងចក្រកាត់ដេរ គឺជាមុខតំណែងពីរនៅក្នុងវិស័យឧស្សាហកម្មឯកជន ដែលជនរួចពីរងគ្រោះកំពុងធ្វើការងារនៅទីនោះយ៉ាងរលូន និងទទួលបានប្រាក់ចំណូលសមរម្យសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។

   **អនុសាសន៍៖** កម្មវិធីសមាហរណកម្ម និងជនរួចពីរងគ្រោះអាចនឹងទទួលបានអត្ថប្រយោជន៍តាមរយៈការបង្កើនដៃគូរសហការជាមួយនឹងយន្តការលើកកម្ពស់វិស័យអាជីវកម្ម ដែលទទួលយកជនរួចពីរងគ្រោះពីការជួញដូរផ្លូវភេទ និង/ឬសមាជិកគ្រួសាររបស់ពួកគេឲ្យធ្វើការជាមួយ។ ការបង្កើតដៃគូរសហការគួរតែពិចារណាឲ្យបានប្រុងប្រយ័ត្នចំពោះតម្រូវការផ្នែកការអប់រំ និងការបណ្តុះបណ្តាលសម្រាប់អតិថិជន និងអាជីវកម្ម ក៏ដូចគ្នានឹងកម្រិតនៃការរក្សាព័ត៌មាន (រឿង

របស់អតិថិជន) ដើម្បីជៀសឲ្យបានពីការមាក់ងាកស្លាកស្នាមទុរយស និងការធ្វើបុរេនិច្ច័យពីសំណាក់អ្នកធ្វើការជាមួយគ្នាទៅលើអ្នកទើបចូលធ្វើការថ្មី។

6. **លទ្ធផលនៃការសិក្សា៖** ការខិតខំប្រឹងធ្វើការ ឬការស៊ូទ្រាំ គឺជាមធ្យោបាយជួយខ្លួនឯងឲ្យឆាប់ត្រលប់មកធម្មតាវិញដែលអាចបង្រៀន ឬបណ្តុះបណ្តាលបាន។ វាជាការសំខាន់សម្រាប់ជីវិតជនរួចពីរងគ្រោះ នៅពេលពួកគេធ្វើសមាហរណកម្មទៅក្នុងស្ថានភាព និងបរិយាកាសដែលមានការលំបាកប្រឈមនានា។ លើសពីនេះទៀត អតិថិជនមួយចំនួនបាននិយាយថា កម្រិតនៃការខំប្រឹងប្រែងធ្វើការងារ បន្ទាប់ពីពួកគេធ្វើសមាហរណកម្មរួច មានការលំបាកជាង បើប្រៀបធៀបទៅនឹងកម្រិតការងារដែលតំរូវឲ្យពួកគេធ្វើនៅពេលរស់នៅក្នុងមណ្ឌល។

   **អនុសាសន៍៖** ការបង្រៀនជនរួចពីរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌលឲ្យយល់អំពីតម្លៃនៃការខំប្រឹងធ្វើការ និងការតស៊ូ នឹងផ្តល់នូវជំនាញដ៏សំខាន់សម្រាប់ពួកគេ នៅពេលពួកគេជួបបទពិសោធន៍ពិបាកៗ និងឧបសគ្គប្រឈមនានានៅក្នុងសហគមន៍របស់ពួកគេនៅពេលអនាគត។

7. **លទ្ធផលនៃការសិក្សា៖** អតិថិជនដែលរៀបការហើយភាគច្រើន កំពុងជួបបញ្ហាក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ។ កម្មវិធីដែលជួយដល់បុរសនៅក្នុងជីវិតអាពាហ៍ពិពាហ៍ ត្រូវតែធ្វើការពិចារណា និងបង្កើតឡើងឲ្យបានល្អិតល្អន់ ដើម្បីឲ្យស្របគ្នាជាមួយកម្មវិធីឈោងចាប់ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ស្ត្រី។

   **អនុសាសន៍៖** កម្មវិធីឈោងចាប់ ជាតំរូវការ ដោយធ្វើការជាមួយមិត្តប្រុស និងស្វាមីរបស់ស្ត្រីដែលរួចពីរងគ្រោះ ជាតម្រូវការ (ធ្វើការដោយផ្ទាល់ប្រសិនបើចាំបាច់ ហើយវាអាស្រ័យទៅទៅលើព័ត៌មានណាដែលជនរួចពីរងគ្រោះចង់ចែកចាយ)។ ធនធានសម្រាប់ផ្តល់ឱវាទ និងសម្រាប់បង្រៀន ជាតម្រូវការចាំបាច់ ដែលជួយលើកកម្ពស់ឲ្យបុរសចូលរួមក្នុងការបង្កើតទំនាក់ទំនងដែលគាំទ្រគ្នាទៅវិញទៅមក និងចេះលើកទឹកចិត្តដល់ភរិយារបស់ពួកគេ។ ប្រភេទនៃកម្មវិធីទាំងនេះគួរតែធ្វើការពិចារណា និងបង្កើតឡើងដោយយកចិត្តទុកដាក់ ដើម្បីឲ្យស្របគ្នាជាមួយកម្មវិធីឈោងចាប់ និងកម្មវិធីបណ្តុះបណ្តាលសម្រាប់ស្ត្រី។

## 5.0 ឯកសារយោង

Crawford, M. and Kaufman, M. R. (2008). "Sex Trafficking in Nepal: Survivor Characteristics and Long-Term Outcomes", *Violence Against Women,* 14(8), 905-916, doi: 10.1177/1077801208320906.

Delaney, A., and Scharff, M. (2010), 'World Faiths Development Dialogue: Faith-Inspired Organizations And Development in Cambodia', World Faiths Development Dialogue (Phnom Penh: Faith-Inspired Organizations & Development in Cambodia), 176.

Derks, A., Henke, R., and Vanna, L. (2006), 'Review of a Decade of Research On Trafficking in Persons, Cambodia', (Phonm Penh, Cambodia: The Asia Foundation, USAID, Center for Advanced Study), 59.

Gray, G. G. (2012). "Resilience in Cambodia: Hearing the Voices of Trafficking Survivors and Their Helpers", (Doctoral dissertation, Doctor of Psychology (PsyD), George Fox University) Digital Commons, Paper 80, 85, available online: http://digitalcommons.georgefox.edu.

Hawkins, S. R., Graham, P. W., Williams, J., & Zahn, M. A. (2009). Resilient girls—factors that protect against delinquency. Washington, DC: U.S. Department of Justice: Office of Juvenile Justice and Delinquency Prevention.

Miles, G. and Miles, S. (2010). *The Butterfly Longitudinal Research Project: End of Year Progress Report 2010*, Chab Dai Coalition.

Miles, G. and Miles, S. (2011). *The Butterfly Longitudinal Research Project: End of Year Progress Report 2011*, Chab Dai Coalition.

Miles, S., Heang, S., Lim, V., Orng L. H., Smith-Brake, J. and Dane, S. (2012). *The Butterfly Longitudinal Research Project: End of Year Progress Report 2012,* Chab Dai Coalition.

Miles, S., Heang, S., Lim, V., Sreang, P. and Dane, S. (2013). *The Butterfly Longitudinal Research Project: End of Year Progress Report 2013*, Chab Dai Coalition.

Morrison, Todd. Miles, Siobhan. Schafer, Priscilla. Heang, Sophal. Lim, Vanntheary. Sreang, Phally. Nhanh, Chhantha. (2014), 'Thematic Paper, Resilience: Survivor Experiences and Expressions ', *The Butterfly Longitudinal Research Project: A Chab Dai study on (Re-)integration: Researching the lifecycle of sexual exploitation & trafficking in Cambodia* (Phnom Penh: Chab Dai), 80.

Muco, E. (2013). "Trafficking in Human Beings: Paradigms of a Successful Reintegration into Society (Albanian Case)", *European Scientific Journal,* 9(4), 92-117.

Noltemeyer, A. L. and Bush, K. R. (2013). "Adversity and Resilience: A Synthesis of International Research", *School Psychology International,* 34(5), 474-487, doi: 10.1177/0143034312472758.

Nowak-Carter, T. (2012), *Resiliency in Survivors of Human Trafficking: An Explanatory Study of Clinicians' Perspectives on Protective Factors*, thesis for a Master of Social Work, Smith College School for Social Work, 117.

Øverland, G. (2012). *Post traumatic survival: a study of Cambodian resilience*. (Doctoral dissertation, Faculty of humanities and education, University of Agder)

Reimer, J.K., Langeler, E., Sophea, S., and Montha, S. (2007), 'The Road Home: toward a model of 'reintegration' and considerations for alternative care for children trafficked for sexual exploitation in Cambodia', (Phnom Penh, Cambodia: Hagar/World Vision Cambodia), 84.

Surtees, R. (2012). *Re/Integration of Trafficked Persons: Supporting Economic Empowerment,* Issue Paper #4, Trafficking Victims Re/integration Programme, King Baudouin Foundation/ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH/NEXUS.

Surtees, R. (2013). *After Trafficking: Experiences and Challenges in the (Re)integration of Trafficked Persons in the Greater Mekong Sub-Region,* UNIAP/NEXUS Institute, 256.

Werner, E. E. (1993). Risk, resilience, and recovery: Perspectives from the Kauai longitudinal study. *Development and psychopathology*, 5(04), 503-515.

Yntiso, G., Gebre, A., Shiferaw, R., & Workineh, H. (2014). *Learning from Children Exposed to Sexual Abuse and Sexual Exploitation: The Bamboo Project Study on Child Resilience-Resilience in Children Living in Merkato, Ethiopia*, Addis Ababa, Ethiopia.